ໃນນັ້ນ, ສາມາດເຫັນໄດ້ຄວາມຈິງໃຈຂອງຝ່າຍລາວ ທີ່ຖືສຳຄັນການພົບປະເຈລະຈາໃນການແກ້ໄຂບັນຫາຊາຍແດນ ກັບທຸກໆປະເທດເພື່ອນບ້ານອ້ອມຂ້າງ ເຖິງວ່າການສຳຫຼວດ ແລະ ກຳນົດເສັ້ນຊາຍແດນຈະມີຄວາມຫຍຸ້ງຍາກສັບສົນນາໆປະການ, ແຕ່ຍ້ອນມີເຈດຕະນາລົມການເມືອງອັນດີ ແລະ ມີຄວາມຕັ້ງໜ້າຢ່າງຈິງໃຈ ຫຼາຍໆບັນຫາຂັດສົນທາງດ້ານຊາຍແດນກໍຖືກແກ້ໄຂຢ່າງເປັນລະບົບ ຍົກຕົວຢ່າງ: ກັບ ສາທາລະນະລັດ ປະຊາຊົນຈີນ ທີ່ມີຊາຍແດນຍາວເຖິງ 505 ກິໂລແມັດ ກໍສາມາດສຳເລັດລຸລ່ວງໄປໄດ້ 100% ແຕ່ປີ 1993 ແລະ ໃນເວລາຕໍ່ມາ ກໍໄດ້ພ້ອມກັນປັກຫຼັກໝາຍຖີ່ຂອງສອງປະເທດສຳເລັດໃນປີ 2012. ກັບ ສະຫະພາບມຽນມາ ເສັ້ນຊາຍແດນແມ່ນໄປຕາມລຳນ້ຳຂອງ ເຊິ່ງສອງປະເທດໄດ້ປັກຫຼັກໝາຍຄູ່ຂະໜານລຽບສອງຝັ່ງ ໄດ້ສຳເລັດ 100% ແຕ່ປີ 1994. ກັບ ສາທາລະນະລັດ ສັງຄົມນິຍົມຫວຽດນາມ ແມ່ນສຳເລັດການປັກຫຼັກໝາຍຊາຍແດນແຕ່ປີ 1987 ເປັນພື້ນຖານ ເຊິ່ງຕໍ່ມາກໍໄດ້ຕົກລົງປັກຫຼັກໝາຍຖີ່ໄດ້ສຳເລັດ 100% ໃນປີ 2016. ມາເຖິງປັດຈຸບັນການເຈລະຈາປັກຫຼັກໝາຍຊາຍແດນກັບຣາຊະອານາຈັກໄທ ແມ່ນສຳເລັດປະມານ 37%, ໃນນີ້ຊາຍແດນທາງບົກສຳເລັດແລ້ວ 93%, ສ່ວນຊາຍແດນທາງນ້ຳຍັງຮ່ວມກັນປຶກສາຫາລື ກ່ຽວ

ກັບຂໍ້ກຳນົດທາງດ້ານເຕັກນິກ ເພື່ອພິຈາລະນາການສຳຫຼວດ ແລະ ປັກຫຼັກໝາຍຊາຍແດນທາງນ້ຳຕໍ່ໄປ ແລະ ຈະໃຊ້ເວລາຕື່ມອີກ.

ບົດຮຽນການແກ້ໄຂບັນຫາຊາຍແດນຂອງລາວ ກັບບັນດາປະເທດດັ່ງກ່າວຂ້າງເທິງນັ້ນກໍໄດ້ໃຊ້ເວລາເປັນຫຼາຍປີ ເຊິ່ງໄດ້ດຳເນີນໄປພາຍໃຕ້ຫຼັກການຂອງສາກົນ ຄື ເຈລະຈາກັນໃນຫຼາຍລະດັບແຕ່ລຸ່ມຂຶ້ນເທິງ ແລະ ແຕ່ເທິງລົງລຸ່ມ ນຳໃຊ້ເອກະສານ ແລະ ແຜນທີ່ກ່ຽວຂ້ອງມາສົມທົບ ແລະ ລົງສຳຫຼວດໃນພາກສະໜາມຕົວຈິງ. ໝາກຜົນທີ່ຍາດມາໄດ້ແມ່ນຜ່ານທາງການທູດຖືວ່າເປັນວິທີການອັນຖືກຕ້ອງ ທັງສອດຄ່ອງກັບຄວາມມຸ້ງມາດປາດຖະໜາຂອງສອງຝ່າຍທີ່ກ່ຽວຂ້ອງ ເພື່ອຊອກຫາຄວາມສົມເຫດສົມຜົນ.

ສຳລັບການສຳຫຼວດ ແລະ ປັກຫຼັກໝາຍຊາຍແດນ ລາວ-ກຳປູເຈຍ ກໍໄດ້ມີຜົນສຳເລັດເປັນທີ່ໜ້າເພິ່ງພໍໃຈມາເປັນສ່ວນຫຼາຍແລ້ວ. ກໍລະນີບໍລິເວນແກ້ງຕໍມໍຄອຍ-ຫ້ວຍຕະເງົາ ຝ່າຍລາວ ກໍໄດ້ອີງໃສ່ຂໍ້ມູນ ແລະ ຫຼັກຖານທາງປະຫວັດສາດ, ພະຍານຈາກຄົນຮຸ່ນກ່ອນ ແລະ ແຜນທີ່ຝຣັ່ງເສດໄດ້ປະໄວ້ຈຳນວນໜຶ່ງ. ເປັນທີ່ເຂົ້າໃຈດີວ່າ ການທີ່ຝ່າຍລາວ ບໍ່ໄດ້ຕອບໂຕ້ຕໍ່ການໃຊ້ກຳລັງບຸກຍຶດ ແລະ ຍຶດຄອງບໍລິເວນແກ້ງຕໍມໍຄອຍ-ຫ້ວຍຕະເງົາ ຂອງຝ່າຍກຳປູເຈຍ ຍ້ອນວ່າຝ່າຍລາວເຄົາລົບນັບຖືການຕົກລົງຂອງສອງຝ່າຍໃນເມື່ອກ່ອນວ່າແມ່ນ "ຈຸດຄົງຄ້າງຊົ່ວຄາວ" ທັງເຊື່ອໝັ້ນວ່າ ຈະສືບຕໍ່ຮ່ວມກັບຝ່າຍກຳປູເຈຍ ພິຈາລະນາປະຕິບັດຕາມຫຼັກການທີ່ໄດ້ຮັບຮອງນຳກັນ. ການກະທຳເຊັ່ນນີ້ ແມ່ນເຈດຕະນາຂອງຝ່າຍກຳປູເຈຍທີ່ຢາກໃຫ້ຝ່າຍລາວ ຍອມຮັບຮູ້ຕາມສະພາບຕໍ່ການຄອບຄອງດິນແດນດ້ວຍການໃຊ້ກຳລັງເຂົ້າບຸກຍຶດ ແລະ ຍຶດຄອງ.

ການກະທຳດ້ວຍເຫດຜົນຂອງຝ່າຍກຳປູເຈຍ ທີ່ອ້າງວ່າ ເປັນອະທິປະໄຕຂອງຕົນ ໂດຍໃຊ້ກຳລັງເພື່ອຄວາມຊອບທຳຂອງຕົນນັ້ນ ບໍ່ເປັນສິ່ງທີ່ໜ້າເຊື່ອຖືສຳລັບປະຊາຊົນກຳປູເຈຍ ແລະ ກໍເປັນທີ່ຮັບບໍ່ໄດ້ສຳລັບປະຊາຊົນລາວ ເພາະເປັນການບໍ່ເຄົາລົບຕໍ່ຂໍ້ຕົກລົງຂອງທັງສອງຝ່າຍ. ຝ່າຍກຳປູເຈຍ ອາດຈະບໍ່ຄຳນຶງເຖິງຜົນສະທ້ອນທີ່ຈະຕາມມາພາຍຫລັງວ່າ ການຄອບຄອງດິນແດນຂອງປະເທດອື່ນໃນໄລຍະຍາວຢ່າງຜິດກົດໝາຍນັ້ນ ຈະບໍ່ເປັນຜົນດີສຳລັບສອງຝ່າຍໃນການແກ້ໄຂ

ບັນຫາໂດຍສັນຕິວິທີ. ການແກ່ຍາວບັນຫາດັ່ງກ່າວ ຍັງຈະສົ່ງຜົນສະທ້ອນຕໍ່ສັນຕິພາບ, ສະຖຽນລະພາບຕາມບໍລິເວນຊາຍແດນຂອງທັງສອງປະເທດ ແລະ ໃນພາກພື້ນອາຊຽນນຳອີກ.

ໃນພາກປະຕິບັດທາງສາກົນໃນການແກ້ໄຂບັນຫາຊາຍແດນຮ່ວມກັນນັ້ນ ຈະສາມາດດຳເນີນຜ່ານການເຈລະຈາສອງຝ່າຍໂດຍສັນຕິວິທີ ຫຼື ທາງເລືອກສຸດທ້າຍກໍສາມາດນຳສະເໜີແກ້ໄຂໂດຍສານຍຸຕິທຳສາກົນ (ສານໂລກ). ຕໍ່ຈຸດຄົງຄ້າງດັ່ງກ່າວ, ສະຖາບັນຄົ້ນຄວ້າວິທະຍາສາດສັງຄົມແຫ່ງຊາດ ໄດ້ວິເຄາະ ແລະ ຕຶກຕອງ ເຊິ່ງທາງເລືອກທີ່ຈະຕອບສະໜອງຜົນປະໂຫຍດອັນສູງສົ່ງຂອງຊາດນັ້ນ ສົມຄວນຈະດຳເນີນໄປຢ່າງສັນຕິ ດ້ວຍສັນຕິວິທີໂດຍສອງຝ່າຍທີ່ກ່ຽວຂ້ອງ.

ສາທາລະນະລັດ ປະຊາທິປະໄຕ ປະຊາຊົນລາວ ແລະ ຣາຊະອານາຈັກກຳປູເຈຍ ຕ່າງກໍເປັນສະມາຊິກຂອງອົງການສາກົນເຊັ່ນ: ສະຫະປະຊາຊາດ, ອາຊຽນ, ສະມາຊິກທະນາຄານໂລກ, ກອງທຶນສາກົນ, ທະນາຄານພັດທະນາອາຊີ ແລະ ອື່ນໆ ທີ່ສຳຄັນໃນນັ້ນທັງສອງປະເທດ ຍັງຖືກອົງການສະຫະປະຊາຊາດຈັດເຂົ້າໃນກຸ່ມປະເທດທີ່ດ້ອຍພັດທະນາຂອງໂລກ. ແນວໃດກໍດີ, ທັງສອງປະເທດກຳລັງພະຍາຍາມອອກແຮງ ເພື່ອນຳເອົາປະເທດຊາດກ້າວອອກຈາກສະພາບທີ່ມີລະດັບເສດຖະກິດຫຼ້າຫຼັງ.

ການຂັດແຍ່ງດ້ານຊາຍແດນ ແມ່ນສິ່ງທີ່ທ້າທາຍ ແລະ ລະອຽດອ່ອນ ເຊິ່ງມີຄວາມຈຳເປັນຕ້ອງແກ້ໄຂບັນຫາໃຫ້ສອດຄ່ອງກັບຄວາມເປັນຈິງ. ຕ້ອງຫຼີກເວັ້ນຄວາມອາດສາມາດທີ່ຈະພາໃຫ້ເກີດມີຄວາມເຄັ່ງຕຶງ ແລະ ພາໄປສູ່ທາງຕັນ. ສາທາລະນະລັດ ປະຊາທິປະໄຕ ປະຊາຊົນລາວ ແລະ ຣາຊະອານາຈັກ ກຳປູເຈຍ ທີ່ມີສາຍພົວພັນທາງການທູດນຳກັນເປັນເວລາ 60 ປີແລ້ວ ຄວນຈະຖະນຸຖະໜອມສາຍພົວພັນອັນດີນັ້ນໄວ້ຕະຫຼອດການ ແລະ ຈະຕ້ອງບໍ່ໃຫ້ມູນເຊື້ອມິດຕະພາບທີ່ເຄີຍມີມານັ້ນມົວໝອງ ແລະ ຖອຍຫຼັງ.

ເປັນຄວາມຈິງທີ່ວ່າ ອຳນາດອະທິປະໄຕ ແລະ ຜືນແຜ່ນດິນອັນຄົບຖ້ວນແມ່ນຝັງເລິກໃນຈິດໃຈຂອງແຕ່ລະຊາດ ເມື່ອມີການລ່ວງລະເມີດ ຕໍ່ອະທິປະໄຕ

ແລະ ຜືນແຜ່ນດິນອັນຄົບຖ້ວນຂອງປະເທດ ແມ່ນຕ້ອງມີການປົກປ້ອງຈົນເຖິງທີ່ສຸດ. ອຳນາດອະທິປະໄຕ ແລະ ຜືນແຜ່ນດິນອັນຄົບຖ້ວນ ແມ່ນມູນມໍລະດົກຂອງຊາດທີ່ຕ້ອງໄດ້ຮັບການປົກປ້ອງ, ແຕ່ການທີ່ຝ່າຍກຳປູເຈຍ ໃຊ້ກຳລັງທະຫານເຂົ້າມາຍຶດຄອງບໍລິເວນແກ້ງຕໍມໍຄອຍ-ຫ້ວຍຕະເງົາ ນັ້ນເປັນການສົ່ງສັນຍານບົ່ງບອກເຖິງການທ້າທາຍໃນການນຳໃຊ້ກຳລັງເພື່ອແກ້ໄຂບັນຫາ ເຊິ່ງຖືວ່າຂັດກັບ ສົນທິສັນຍາມິດຕະພາບ ແລະ ຊ່ວຍເຫຼືອເຊິ່ງກັນ ແລະ ກັນ ກໍຄື 04 ຫຼັກການທີ່ໄດ້ກຳນົດອອກໃນບົດບັນທຶກ ລະຫວ່າງ ຄະນະກຳມາທິການຊາຍແດນຂອງສອງປະເທດລາວ ແລະ ກຳປູເຈຍ.

ເນື້ອໃນຈິດໃຈຂອງກົດບັດສະຫະປະຊາຊາດ ແມ່ນຢາກຊຸກຍູ້ໃຫ້ສ້າງເງື່ອນໄຂທີ່ເອື້ອອຳນວຍກໍ່ໃຫ້ເກີດຄວາມຍຸດຕິທຳ ແລະ ນັບຖືພັນທະໜ້າທີ່ທີ່ລະບຸໄວ້ໃນສົນທິສັນຍາ ແລະ ກົດໝາຍສາກົນ. ຄຽງຄູ່ກັນນີ້, ກົດບັດສະຫະປະຊາຊາດ ຍັງໄດ້ລະບຸວ່າ “ຄວນສະແດງຄວາມອົດກັ້ນ ແລະ ຢູ່ຮ່ວມກັນໂດຍສັນຕິ ໃນຖານະເພື່ອນບ້ານໃກ້ຄຽງທີ່ດີຕໍ່ກັນ, ບໍ່ນຳໃຊ້ກຳລັງຕໍ່ກັນ, ຮັກສາຜົນປະໂຫຍດຮ່ວມກັນດ້ວຍການຍອມຮັບຫຼັກການ ແລະ ວິທີການຂອງບັນດາສະຖາບັນຕ່າງໆ”. ການທີ່ ສາທາລະນະລັດ ປະຊາທິປະໄຕ ປະຊາຊົນລາວ ແລະ ຣາຊະອານາຈັກ ກຳປູເຈຍ ຫາທາງອອກຢ່າງສັນຕິຕໍ່ຂໍ້ຂັດແຍ່ງໃນບໍລິເວນຊາຍແດນລ້ວນແລ້ວແຕ່ແມ່ນການປະກອບສ່ວນຕໍ່ການຮັກສາສັນຕິພາບ, ສະຖຽນລະພາບ ແລະ ຄວາມໝັ້ນຄົງໃນພາກພື້ນ ແລະ ໃນໂລກ.

ນອກຈາກກົດບັດສະຫະປະຊາຊາດແລ້ວ, ກົດບັດອາຊຽນ ກໍໄດ້ລະບຸໃນມາດຕາ 02 ຂໍ້ 02 ວ່າ:

(ກ) ເຄົາລົບເອກະລາດ, ອະທິປະໄຕ, ຄວາມສະເໝີພາບ ແລະ ຜືນແຜ່ນດິນອັນຄົບຖ້ວນ ແລະ ເອກະລັກແຫ່ງຊາດຂອງທຸກໆປະເທດອາຊຽນ;
(ຂ) ບໍ່ໃຊ້ກຳລັງຮຸກຮານ ແລະ ຂົ່ມຂູ່ ຫຼື ໃຊ້ກຳລັງ ຫຼື ການກະທຳທຸກຮູບແບບທີ່ບໍ່ສອດຄ່ອງກັບກົດໝາຍສາກົນ;
(ຄ) ຍຶດໝັ້ນໃນການແກ້ໄຂຂໍ້ຂັດແຍ່ງໂດຍສັນຕິວິທີ.

ຄວາມຮັບຜິດຊອບຕໍ່ການແກ້ໄຂບັນຫາ ບໍ່ພຽງແຕ່ ແມ່ນວຽກຂອງຄະນະກໍາມາທິການຊາຍແດນຂອງສອງປະເທດເທົ່ານັ້ນ, ແຕ່ທັງສອງຝ່າຍ ຍັງຈະຕ້ອງກວດກາຄືນເຖິງຄວາມຜິດພາດທາງດ້ານເຕັກນິກໃນໄລຍະຜ່ານມາ. ທັງສອງຝ່າຍຕ້ອງຕັ້ງໜ້າແກ້ໄຂບັນຫາດ້ວຍການວາງຍຸດທະສາດທີ່ມີປະສິດທິພາບ ເພື່ອຫລຸດຜ່ອນການຂັດແຍ່ງກັນ, ຕ້ອງມີຄວາມຈິງໃຈ ແລະ ບໍ່ລະແວງສົງໄສກັນ, ຕ້ອງມີການຮັບປະກັນຕໍ່ກັນວ່າຈະສຸມໃສ່ແກ້ໄຂບັນຫາໃຫ້ລຸລ່ວງໂດຍດີ.

ວິທີທາງທີ່ດີໃນເວລາເຈລະຈາກັນ ແມ່ນສະເໜີໃຫ້ວິຊາການທາງດ້ານກົດໝາຍສາກົນ ຊອກຫາຕົ້ນປາຍສາເຫດຂອງບັນຫາທີ່ກໍ່ໃຫ້ເກີດການຂັດແຍ່ງກັນທາງຊາຍແດນວ່າມາຈາກການຕີຄວາມໝາຍ ແລະ ຄວາມເຂົ້າໃຈດ້ານແຜນທີ່ ຄືນລະຄວາມຄິດ ຫຼື ແນວໃດ ຫຼືວ່າ ມີເຈດຕະນາຢາກໃຫ້ຝ່າຍໜຶ່ງຕົກໃນເລ່ກົນຫຼອກລວງ. ຕາມບົດຮຽນຂອງຫຼາຍປະເທດໃນໂລກ ການແກ້ໄຂບັນຫາຊາຍແດນແມ່ນໃຊ້ເວລາຫຼາຍປີ, ບໍ່ແມ່ນຈະເອົາບັນຫາອື່ນແຊກຊ້ອນເຂົ້າມາເພື່ອສ້າງສະຖານະການ ຫາກຂາດຄວາມໂປ່ງໃສ ມີຄວາມລະແວງເຊິ່ງກັນ ແລະ ກັນ ກໍຈະບໍ່ສາມາດຜ່ານຜ່າອຸປະສັກຫຍຸ້ງຍາກໄດ້. ທັງສອງຝ່າຍ ຄວນເຂົ້າໃຈກັນ ແລະ ຕ້ອງຫຼີກເວັ້ນການນໍາເອົາກໍາລັງທະຫານເຂົ້າມາຂົ່ມຂູ່ແກ້ໄຂບັນຫາ ອັນຈະພາໃຫ້ມີການເພີ່ມເຕີມຄວາມເປັນປໍລະປັກກັນໃນຍຸກໃໝ່ ເຊິ່ງຈະຖືກປະຫວັດສາດຂອງສອງປະເທດກ່າວປະນາມ.

ບົດຮຽນທີ່ຝ່າຍລາວ ປະສົບຜົນສໍາເລັດໃນການຂີດເສັ້ນຊາຍແດນກັບສາທາລະນະລັດ ປະຊາຊົນຈີນ, ສາທາລະນະລັດ ສັງຄົມນິຍົມ ຫວຽດນາມ ແລະສະຫະພາບມຽນມານັ້ນ ກໍແມ່ນມາຈາກຄວາມຈິງໃຈ, ຢຶດຖືຄວາມສະເໝີພາບ, ການຕອບສະໜອງເຊິ່ງກັນ ແລະ ກັນ, ການນັບຖື ແລະ ປະຕິບັດຕາມສົນທິສັນຍາ ແລະ ສັນຍາທີ່ຝຣັ່ງເສດປະໄວ້ໃຫ້ລາວ ໃນຖານະຜູ້ສືບທອດ ແລະກໍພ້ອມກັນປະຕິບັດຢ່າງຕັ້ງໜ້າ.

ຄະນະຄົ້ນຄວ້າປະຫວັດສາດການພົວພັນ ລາວ-ກໍາປູເຈຍ ຂອງສະຖາບັນວິທະຍາສາດສັງຄົມແຫ່ງຊາດ ມີຄວາມເຊື່ອໝັ້ນວ່າ ຄວາມໝັ້ນຄົງ ແລະສະຖຽນລະພາບທາງການເມືອງ ແມ່ນບັນຫາບູລິມະສິດ ເພື່ອນໍາພາປະເທດຊາດ

ພັດທະນາກ້າວຂຶ້ນ ແນໃສ່ໃຫ້ຫຼຸດພົ້ນອອກຈາກຄວາມດ້ອຍພັດທະນາ ເພື່ອຄວາມກ້າວໜ້າສີວິໄລທາງສັງຄົມ. ແນວໃດກໍດີ, ເປັນທີ່ຮູ້ກັນວ່າ ເນື້ອແທ້ຂອງຄວາມໝັ້ນຄົງນັ້ນ ແມ່ນບັນຫາທີ່ກວ້າງຂວາງ ທີ່ກວມເອົາທັງປັດໄຈພາຍໃນ ແລະ ພາຍນອກ. ຈົດໝາຍທີ່ທ່ານ ນາຍົກລັດຖະມົນຕີ ສາທາລະນະລັດ ປະຊາທິປະໄຕ ປະຊາຊົນລາວ ແລະ ຣາຊະອານາຈັກ ກຳປູເຈຍ ເຊັນຮ່ວມກັນ ເຖິງ ພະນະທ່ານ ເອັມມານູແອນ ມາກຣົງ, ປະທານາທິບໍດີຝຣັ່ງເສດ ສະບັບລົງວັນທີ 06 ກັນຍາ 2017 ແລະ ຈົດໝາຍຕອບຂອງປະທານາທິບໍດີຝຣັ່ງເສດ, ສະບັບລົງວັນທີ 23 ຕຸລາ 2017 ທີ່ໃຫ້ການສະໜັບສະໜູນຢ່າງເຕັມປ່ຽມຕໍ່ຄວາມພະຍາຍາມຂອງທັງສອງລັດຖະບານ ໃນການກຳນົດເສັ້ນຊາຍແດນຮ່ວມຂອງສອງປະເທດ ດ້ວຍການເຄົາລົບຕໍ່ກົດໝາຍສາກົນ ພ້ອມທັງຈະມອບໝາຍໃຫ້ພາກສ່ວນກ່ຽວຂ້ອງທີ່ຊຳນານງານດ້ານເຕັກນິກໃຫ້ການຮ່ວມມື, ລວມທັງເອກະສານຕ່າງໆທີ່ຝຣັ່ງເສດຈະສະໜອງໃຫ້ບົນພື້ນຖານຂໍ້ກຳນົດທາງດ້ານເຕັກນິກທີ່ໄດ້ມີການຕົກລົງກັນແລ້ວລະຫວ່າງ ລາວ ແລະ ກຳປູເຈຍ ນັ້ນຖືເປັນສັນຍານທີ່ດີ.

ສະຫຼຸບແລ້ວ, ການແກ້ໄຂບັນຫາຊາຍແດນດ້ວຍສັນຕິວິທີ ແມ່ນທາງອອກທີ່ດີ ທີ່ລັດຖະບານ ແລະ ປະຊາຊົນສອງຊາດ ລາວ ແລະ ກຳປູເຈຍ ຄວນໃຫ້ຄວາມສຳຄັນ ແລະ ເອົາໃຈໃສ່ຢ່າງຕັ້ງໜ້າ ໂດຍອີງໃສ່ຫຼັກການແຫ່ງມູນເຊື້ອມິດຕະພາບອັນຍິ່ງໃຫຍ່ ແລະ ຄວາມສາມັກຄີອັນແໜ້ນແຟ້ນຖານປະເທດບ້ານໃກ້ເຮືອນຄຽງທີ່ມີມາຫຼາຍເຊັ່ນຄົນແລ້ວນັ້ນ ແລະ ກໍຕ້ອງໃຫ້ສອດຄ່ອງກັບບັນດາຫຼັກການແຫ່ງກົດໝາຍສາກົນ.

----------

| | |
|---|---|
| ຊື່ປຶ້ມ: | ຄວາມເປັນຈິງກ່ຽວກັບຈຸດຄົງຄ້າງເສັ້ນຊາຍ ແດນ ລາວ-ກຳປູເຈຍ |
| ພິມຄັ້ງທີ: | 1 |
| ພາສາພິມ: | ພາສາລາວ, ພາສາຂະແມ ແລະ ພາສາ ອັງກິດ |
| ອົງການທີ່ຈັດພິມ: | ສະຖາບັນວິທະຍາສາດສັງຄົມແຫ່ງຊາດລາວ |
| ຂະໜາດປຶ້ມ: | 21 x 15 ຊມ |
| ຈຳນວນໜ້າ: | 126 ໜ້າ |
| ຈຳນວນຈັດພິມ: | 5.000 ຫົວ |
| ຈຸດປະສົງໃນການພິມ: | ແຈກຢາຍລ້າ |

# ភាពពិត
# នៃចំណុចនៅសេសសល់
# រវាងខ្សែព្រំដែនឡាវ - កម្ពុជា

**វិទ្យាស្ថានវិទ្យាសាស្ត្រសង្គមជាតិ**

**បោះពុម្ពដោយរោងចក្របោះពុម្ពរដ្ឋ**

2018

# មាតិកា


| | | | |
|---|---|---|---|
| បុព្វកថា | | | 1 |
| **ជំពូក ទី I** | | ប្រភពប្រវត្តិប្រវត្តិសាស្ត្រនៃទំនាក់ទំនងរវាងឡាវនិងកម្ពុជា | 4 |
| | 1. | ការទំនាក់ទំនងរវាងឡាវនិងកម្ពុជានៅក្នុងក្របខ័ណ្ឌសហព័ន្ធឥណ្ឌូចិន- បារាំង | 4 |
| | 2. | ទំនាក់ទំនងឡាវ - កម្ពុជា ចាប់តាំងពីដំណាក់កាលតស៊ូ ដើម្បីឯករាជ្យរហូតមកដល់ពេលបច្ចុប្បន្ន | 6 |
| **ជពូក ទី II** | | កិច្ចព្រមព្រៀងរវាងប្រទេសទាំងពីរក្នុងការចុះត្រួតពិនិត្យ និង បោះបង្គោលព្រំដែន | 9 |
| | 1. | ស្ថានភាពនៃការចុះត្រួតពិនិត្យ និង បោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរ | 12 |
| | 2. | ចំណុចនៅសេសសល់រវាងព្រំដែននៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង ព្រះរាជាណាចក្រកម្ពុជា | 13 |
| | 3. | កិច្ចព្រមព្រៀងគ្នារបស់ភាគីទាំងពីរអំពីតំបន់ចំណុចនៅសេសសល់នៅកែងតម៉រខោយ - អូរតង៉ាវ | 20 |
| | 4. | ព្រឹត្តិការណ៍ដែលកើតឡើងនៅតាមតំបន់ព្រំដែននិងការខិតខំដោះស្រាយតាមរយៈការទូតនិងយន្តការផ្លាស់ប្តូរការងារនៃភាគីទាំងពីរ | 23 |
| **ជំពូកទី III** | | ដំណោះស្រាយដ៏សមស្រប់ហេតុផល | 31 |
| | 1. | ទឹសដៅក្នុងការពង្រឹងពង្រីកទំនាក់ទំនងមិត្តភាពរវាងប្រជាជនទាំងពីរ ឡាវ - កម្ពុជា | 31 |
| | 2. | តម្រូវការនៃប្រទេសទាំងពីរនិងទស្សនៈផ្ទុយរបស់ភាគីកម្ពុជា | 35 |
| | 3. | លទ្ធភាពនៃការដោះស្រាយបញ្ហានាពេលអនាគត | 37 |

# ភាពពិតនៃចំណុចនៅសេសសល់ រវាងខ្សែព្រំដែនឡាវ - កម្ពុជា

## បុព្វកថា

ឡាវនិងកម្ពុជា ជាប្រទេសជិតខាងដែលមានប្រពៃណីសាមគ្គីភាព, មានសេចក្តីស្រឡាញ់រាស់អានគ្នា, ជួយគ្នាទៅវិញទៅមកចាប់តាំងពីសម័យបុរាណម្ល៉េះ។ ប្រទេសទាំងពីរមានភាសានិយាយ, តួរអក្សរសរសេរ, ទំនៀមទម្លាប់ប្រពៃណី, ប្រវត្តិ សាស្ត្រនិងវប្បធម៌ ដែលជាអត្តសញ្ញាណរបស់រៀងៗខ្លួនយូរយារមកហើយ។ កាលពីអតីតកាលប្រជាជនប្រទេសទាំងពីរឡាវ និង កម្ពុជា តែងតែទៅមករកគ្នានិងបានផ្លាស់ប្តូរទំនិញនិងធ្វើពាណិជ្ជកម្ម តាមបណ្តោយព្រំដែន នៃប្រទេសទាំងពីរជាមួយគ្នាជានិច បូពាក់បូរសជីដូនជីតារបស់ឡាវនិងខ្មែរជាច្រើនយុគសម័យធ្លាប់មានទំនាក់ទំនងដ៏ជិតស្និទ្ធនិងជាប្រទេសជន្លងនឹងគ្នា ដែលមានចារឹកនៅក្នុងទំព័រប្រវត្តិសាស្ត្រសម័យបុរាណចាប់តាំងពីសម័យព្រះចៅ ហ្វាងឹម នោះជាដើម[1]។ ជាពិសេស, ព្រះអង្គជាស្តេចដ៏អស្ចារ្យរបស់ប្រជាជនឡាវ គឺជាស្តេចមានស្មារតីក្លាហាន, ខ្លាំងពូកែ។ ព្រះអង្គបានដឹកនាំប្រជាពលរដ្ឋបង្កើតកងទ័ពដ៏រឹងមាំ, ពូកែរហើយបានបង្រួបបង្រួម បណ្តាស្រុកផ្សេងៗរបស់ឡាវហើយបានបង្កើតជាអានាចក្រមួយគឺអាណាចក្រឡានសាង ដ៏ល្បីល្បាញ ដែលជះអំណាចឥទ្ធិពលខ្លាំងក្លាដែលគេស្គាល់, ភ័យខ្លាចអំពីបារមីឧត្តុង្គឧត្ត ដែលត្រូវបានបណ្តាអានាចក្រជិតខាងផ្សេងៗ ផ្តល់កិត្តិយសនិងគោរព។

[1] មហា ស៊ីឡា វីឡាវ៉ង់ ៖ ប្រវត្តិសាស្ត្រឡាវពីសម័យបូរានដល់ឆ្នាំ 1946. បោះពុម្ពនៅ រោងពុម្ពម៉ានថាតុគាត់ វៀងច័ន្ទ. 2001, ទំព័រ 30 – 48.

ទោះបីក្នុងប្រវត្តិសាស្ត្រនៃប្រទេសទាំងពីរ ធ្លាប់មានភាពរុងរឿងក៏ដោយ ក៏ប៉ុន្តែក្រោយមកស្ថិតនៅក្រោមឥទ្ធិពលរបស់បរទេសតែប្រទេសទាំងពីរមិនដែលកំណត់ព្រំប្រទល់ច្បាស់លាស់ជាមួយគ្នាទេ។ ប្រទេសទាំងពីរសុទ្ធតែមានការទទួនស្គាល់អំពីជិវៈភាពរស់នៅរបស់ប្រជាជនឡាវ, ប្រជាជនកម្ពុជាដែលយោងទៅតាមការគ្រប់គ្រងជាក់ស្តែងនៃប្រវត្តិសាស្ត្រនៅយុគសម័យនិមួយៗ រហូតដល់ជំនាន់បារាំងចូលមកគ្រប់គ្រងឡាវ, កម្ពុជានិងវៀតណាម។

មកដល់សតវត្សទី 21, ប្រទេសទាំងពីរឡាវ-កម្ពុជា បានសំដៅទៅលើការអភិវឌ្ឍប្រទេសជាតិរៀងៗខ្លួន។ ប៉ុន្តែហេតុការមួយដែលនឹកស្មានមិនដល់ក៏បានកើតឡើងនៅក្នុងទំនាក់ទំនងជាប្រពៃណីដ៏ល្អប្រសើរនៃប្រទេសទាំងពីរនៅពេលដែលកម្ពុជាបានកសាងផ្លូវថ្នល់និងកិច្ចការផ្សេងៗ នៅតាមតំបន់ដែលចាត់ទុកថា ជាតំបន់នៅសេសសល់ព្រំដែននិងមិនទាន់សម្រេចការកំណត់នូវចំណុចបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរនៅឡើយ។ ក្នុងពេលកន្លងមក ភាគីទាំងពីរបានឯកភាពគ្នាថា នឹងគ្មានកិច្ចការសាងសង់អ្វីៗទាំងអស់រហូតដល់កាលណាសម្រេចការកំណត់ព្រំដែននិងបោះបង្គោលសស្រេចជាស្ថាពរ។

ប៉ុន្តែស្ថានភាពទាំងឡាយមានការប្រែប្រួល ដោយគ្មានអត្ថប្រយោជន៍ដល់ទំនាក់ទំនងនៃភាគីទាំងពីរ។ ដូច្នេះវិទ្យាស្ថានវិទ្យាសាស្ត្រសង្គមជាតិបានបង្កើតក្រុមបច្ចេកទេសមួយដំណើរការស្រាវជ្រាវដើម្បីពិនិត្យ, ស៊ើបអង្កេតស្វែងរកអំពីមូលហេតុ, ភាពពិតជាក់ស្តែងខាងប្រវត្តិសាស្ត្រនៃការបែងចែកព្រំដែនរវាងប្រទេសឡាវ-កម្ពុជា និងសំណើរនូវនិតិវិធិដោះស្រាយមួយចំនួនផងដែរ ដើម្បីផ្តល់ចំណេះដឹងជូនប្រជាជនឡាវក៏ដូចជាអន្តរជាតិ អោយយល់ដឹងច្បាស់លាស់, ត្រឹមត្រូវ អំពីមូលហេតុនៃបញ្ហាដែលបានកើតឡើងទាំងនោះសំដៅកសាងតំបន់ព្រំដែនអោយក្លាយទៅជាព្រំដែននៃសន្តិភាព, មិត្តភាព

និងសហប្រតិបត្តិការ។ ដូច្នេះ, វិទ្យាស្ថានវិទ្យាសាស្រ្តសង្គមជាតិ បានបង្ហាញនូវភាពជាក់ស្តែងពិតប្រាកដអំពីចំណុនៅសេសសល់ព្រំដែនឡាវ-កម្ពុជា ដើម្បីធ្វើឱ្យប្រជាជនឡាវ, ប្រជាជនកម្ពុជានិង អន្តរជាតិបានយលដឹងជាសាកល។

# ជំពូក ទី I

# កំណើតប្រវត្តិប្រវត្តិសាស្ត្រនៃទំនាក់ទំនងរវាង ឡាវ និង កម្ពុជា

## 1. ការទំនាក់ទំនងរវាងឡាវនិងកម្ពុជានៅក្នុងក្របខ័ណ្ឌសហព័ន្ធឥណ្ឌូចិន - បារាំង

ឡាវ-កម្ពុជា-វៀតណាម ត្រូវបានកាន់កាប់និងនៅក្រោមអាណានិគមបារាំង ក្នុងពេលវេលាដំណាលគ្នា ដែលអាចសមស្របទៅតាមគោលនយោបាយពង្រីកអាណានិគម ដោយផ្អែកទៅលើកត្តាអំណោយដ៏សំខាន់។ ពួកបារាំងបានចូលលុកលុយភាគខាងត្បូងប្រទេសវៀតណាមនៅចុងឆ្នាំ 1850 និងលុះមកដល់ឆ្នាំ 1860 បានចាប់ផ្តើមបង្រីកឥទ្ធិពលទៅលើភូមិភាគកណ្តាលនិងភូមិភាគខាងជើងប្រទេសវៀតណាម។ បន្ទាប់មក នៅក្នុងឆ្នាំ 1883 ក៏បានគ្រប់គ្រងទឹកដីវៀតណាមទាំងស្រុង ហើយពួកវាក៏បានបែងចែកជាតំបន់ 3 គឺ៖ ទុងកេង, អាណ្ណាមនិងកូសេងសិន ហើយចាត់ទុកអាណ្ណាមជាតំបន់អភិរក្ស ដោយសារតែមានស្តេចនៅឡើយនិងយកតំបន់ពីរគឺ៖ ទុងកេងនិងកូសេងសិន ស្ថិតស្ថេរក្រោមអាណានិគមផ្ទាល់របស់គេ។ លុះមកដល់ឆ្នាំ 1863 បារាំងបានធ្វើដំណើរទៅកាន់កាប់គ្រប់គ្រងប្រទេសកម្ពុជា ហើយក្រោយមកទៀតបានប្រកាសកម្ពុជា ជាតំបន់អភិរក្ស ហើយបានបង្កើតសហព័ន្ធឥណ្ឌូចិននៅឆ្នាំ 1887។ ក្រោយមកនៅក្នុងឆ្នាំ 1893 បារាំងបានគ្រប់គ្រងប្រទេសឡាវ ហើយបន្ទាប់មកបានបែងចែក ខេត្តលួងប្រាបាង ទៅជាតំបន់អភិរក្ស និង បែងចែកភូមិភាគកណ្តាលនិងភូមិភាគខាងត្បូងនៃប្រទេសឡាវ ជាអាណានិគមដោយផ្ទាល់។ បន្ទាប់មកទៀតបារាំងបានបន្ចូលប្រទេសឡាវស្ថិតនៅក្រោមសហព័ន្ធឥណ្ឌូចិន ធ្វើអោយប្រទេសទាំងបីមានជោគវាសនាដូចតែគ្នា។ ចាប់តាំងពីពេលនោះមក ប្រទេសទាំងបីមិនមានសិទ្ធិធ្វើជា

ម្ចាស់នៃប្រទេសរបស់ខ្លួន។ ពួកបារាំងបានតែងតាំងទេសាភិបាលជាន់ខ្ពស់ប្រចាំនៅទីក្រុងហាណូយ ដើម្បីគ្រប់គ្រង់និងត្រួតត្រាលើតំបន់ផ្សេងៗ នៃប្រទេសឡាវ, វៀតណាម និងកម្ពុជា។ រីឯនៅក្នុងតំបន់ដ៏ទៃទៀត ពួកគេក៏បានតែងតាំងស្នងការឈ្មួរប្រចាំការ ដើម្បីគ្រប់គ្រងនិងអភិបាលកិច្ចដោយពេញសិទ្ធិ សូមបីតែរតំបន់អភិរក្សក៏ធ្វើជាអាណានិគមដូរគ្នា។ តំបន់ព្រំដែនធម្មជាតិនៃប្រទេសទាំងបីត្រូវបានផ្សារភ្ជាប់ទៅនឹងសហព័ន្ធឥណ្ឌូចិនបារាំង ហើយពួកបារាំងក៏បានប្រញាប់ដំណើរការកំណត់ព្រំដែនរវាងឥណ្ឌូចិនជាមួយប្រទេសចិន, ភូមានិងសៀម(ប្រទេសថៃ) ដើម្បីបន្តគ្របដណ្តប់និងគ្រប់គ្រងដោយសមស្របតាមច្បាប់ក្នុងនាមជាម្ចាស់នៃអាណានិគមឥណ្ឌូចិន។ ដូចបានដឹងហើយដែរថា នៅក្នុងប្រទេសឡាវ, ពួកបារាំងបានបែងចែកទំហំដីនិងតំបន់នៃអភិបាលកិច្ចរបស់ខ្លួនជាពីរគឺ ៖ ប្រទេសឡាវភាគខាងលើនិងឡាវភាគខាងក្រោម។ ចំពោះឡាវភាគខាងក្រោមនេះមានព្រំដែនជាប់ជាមួយនឹងប្រទេសកម្ពុជាដែលមានផ្ទៃដីទាំងអស់ 108.200 គីឡូម៉ែក្រឡា និងត្រូវបានបែងចែកជាតំបន់បញ្ជាដោយទេសាភិបាលបារាំងដូចជា ៖ ខេត្តស្ទឹងត្រែង, ស្រុកខោង, ខេត្តអាត់តាពឺ, បាន់មួង(ភូមិស្វាយ), សារ៉ាវ៉ាន់, សាវណ្ណខេតនិងមាត់ទន្លេហ៊ីនប៊ូន[2]។ ដោយឡែកនៅខេត្តស្ទឹងត្រែង នេះនាឆ្នាំ 1901 អាជ្ញាធរបារាំងបានស្រង់ស្ថិតិប្រជាពលរដ្ឋរស់នៅក្នុងខេត្តដែលមានការកត់ត្រា នៅក្នុងនោះមានជនជាតិឡាវរស់នៅ នៅទីនេះ 60.000 នាក់, ជនជាតិចិននិងវៀតណាម 140 នាក់និងជនជាតិអឺរប 9 នាក់តែប៉ុណ្ណោះទេ[3]។

---

[2] Eugène Picanon; Le Laos Français avec carte politique de l' Indochine, Paris, Augustin CHALLAMEL – Editeur, page 2-55.

## 2. ទំនាក់ទំនងឡាវ - កម្ពុជា នៃដំណាក់កាលតស៊ូ ដើម្បីឯករាជ្យជាតិរហូតមកដល់ពេលបច្ចុប្បន្ន

ក្នុងឆ្នាំ 1951 ប្រទេសទាំងបី ឡាវ, វៀតណាមនិងកម្ពុជា បានរួមគ្នាបង្កើតរណសិរ្សសម្ព័ន្ធភាពប្រ ជាជនជាតិបី បានរួមគ្នាប្រយុទ្ធប្រឆាំងនឹងរំដោះខ្លួនអោយផុតពីនឹមកាន់កាប់របស់អាណានិគមនិយមបា រាំង ដើម្បីឯករាជ្យជាតិ។ សម្តេច នរោត្តម សីហានុ បានអនុវត្តនូវគោលនយោបាយអព្យាក្រឹតរបស់កម្ពុជា បានរួមចំណែកគ្រាំទរអោយមានកិច្ចប្រជុំសើុនែវ ស្តីពី អព្យាក្រឹតនៅប្រទេសឡាវនៅឆ្នាំ 1962។ ក្រោយពីត្រូវឧត្តមសេនីយ៍ លន់ នល់ ធ្វើរដ្ឋប្រហារ, សម្តេច នរោត្តម សុីហានុ បានភាសខ្លួនទៅប្រទេសចិន ក្រោយមកទ្រង់បានគាំទ្ររពីបណ្តាប្រទេសមិតភក្តិនិងបានចូលរួមកិច្ចប្រជុំរបស់រណសិរ្សសាមគ្គីជាតិប្រទេសបីនិងភាគី 4 គឺ ៖ រណសិរ្សឡាវស្នេហាជាតិ, រណសិរ្សបង្រួបបង្រួមជាតិ សាធារណរដ្ឋប្រ ជាធិបតេយ្យវៀតណាម, រដ្ឋភិបាលបណ្តោះអាសន្នវៀតណាមខាងត្បូងនិងរណសិរ្សសាមគ្គីជាតិកម្ពុជាដែលដឹកនាំដោយសម្តេច នរោត្តម សីហានុ ដែលបានប្រារព្ធនៅហ្គួងចូវ ប្រទេសចិន ពីរដងនៅចុងឆ្នាំ 1970 និងនៅឆ្នាំ 1974។ ក្រោមការគាំទ្រ, ជំនួយរបស់រណសិរ្សសម្ព័ន្ធភាពនៃប្រជាជនជាតិបី, សម្តេច នរោត្តម សីហានុ បានទទួលការជួយឧបត្ថម្ភគាំទ្រពីកងទ័ពរំដោះប្រជាជនវៀតណាម ដោយការឆ្លងកាត់តាមរយៈតំបន់រំដោះភាគខាងត្បូងរបស់ប្រទេសឡាវទៅកាន់ខេត្ត រត្តនគីរី ដើម្បីជំរុញនៃការតស៊ូរបស់ប្រជាជនកម្ពុជា ក្រោមការដឹកនាំរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ប្រឆាំងនឹងអំណាចការគ្រប់គ្រងរបស់ ឧត្តមសេនីយ៍ លន់ នល់។ សម្ព័ន្ធភាពប្រយុទ្ធរវាងឡាវ, កម្ពុជានិងវៀតណាម នៅពាក់កណ្តាលឆ្នាំ 1970 បាននាំមកនូវជ័យជំនះជូនប្រជាជនប្រទេសទាំងបីក្នុងឆ្នាំ 1975។

នៅអំឡុងឆ្នាំ 1976–1979 ខ្មែរក្រហមកាន់កាប់អំណាច ដែលបានតំណើរនយោបាយប្រឡៃពូជសាស្រ ប្រជាជនកម្ពុជារាប់ពាន់នាក់បានភាសខ្លួនឆ្លង

ដែនទៅរស់នៅក្នុងទឹកដីឡាវ។ ក្នុងចំនួនប្រជាជនកម្ពុជាដែលគេចខ្លួនមករស់នៅភាគខាងត្បូងឡាវពេលនោះ មានទាំងកងកម្លាំងប្រដាប់អាវុធ។ ជនធ្លាប់ធ្វើការជាមួយអង្គការអភិបាលមូលដ្ឋាន, កសិករដែលបានប្រកបមុខរបរនៅតាមមូលដ្ឋាននេះ ពេលបានចូលមករស់នៅលើទឹកដីឡាវហើយ ភាគីឡាវក៏បានផ្តល់ការងារអោយគេធ្វើតាមការសមគ្គចិត្ត ដូចជា៖ បន្ទូលគេនៅកងកម្លាំងប្រដាប់អាវុធឡាវ, ការងារគ្រប់គ្រង, ជួលដូរតាមការសមគ្គចិត្តនិងរកស៊ីនូវមុខរបរដាំដុះនិងចិញ្ចចើមសត្វ ឬ ប្រកបមុខវិជ្ជាជីវៈផ្សេងៗទៀតជាទៀងទាត់។ ក្រោយពីរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានបង្កើតឡើងក៏មានមនុស្សមួយចំនួនសមគ្គចិត្តចូលរួមប្រយុទ្ធតស៊ូប្រឆាំងនិងពួកខ្មែរក្រហមរួមចំណែកក្នុងភារកិច្ចរំដោះអោយផុតពីអំណាចគ្រប់គ្រងរបស់ពួកខ្មែរក្រហមនៅថ្ងៃ 7 ខែ មក្ករា ឆ្នាំ 1979។

បន្ទាប់មក ទំនាក់ទំនងនិងកិច្ចសហការរវាងប្រទេសឡាវនិងកម្ពុជាក៏បានពង្រីកពង្រឹងនិងមានការអភិវឌ្ឍជានិច មិនថានៅរយៈដែលប្រទេសបានស្ថាបនាជាប្រទេសសាធារណរដ្ឋ ប្រជាមានិតកម្ពុជា ក្រោយពេលផ្តលរំលំរបបប្រលៃពូជសាស្រ ក៏ដូចជាក្នុងដំណាក់កាលក្រោយពីដំណោះស្រាយបញ្ហាផ្ទៃក្នុងកម្ពុជាដោយភាគីបាស់បាល់ ដែលឈានទៅដល់ការចុះហ្តលេខាលើកិច្ចព្រមព្រាងសន្តិភាពមួយនៅទីក្រុងបារី នាឆ្នាំ 1991 បន្ទាប់មកក៏បានរៀបចំការបោះឆ្នោតជាសកលនៅក្នុងឆ្នាំ 1993។ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានបន្តគាំទ្រនិងទទួលស្គាល់យ៉ាងស្មោះត្រង់នូវការផ្លាស់ប្តូរផ្ទៃក្នុងរបស់ប្រទេសកម្ពុជា។ ប្រទេសទាំងពីរ មានការផ្លាស់ប្តូរទស្សនៈកិច្ចជាផ្លូវការរវាងគណៈប្រតីភូជាន់ខ្ពស់ថ្នាក់ប្រមុខរដ្ឋ, នាយករដ្ឋមន្ត្រី, ប្រធានរដ្ឋសភានិងក្រុមប្រតិភូនៃក្រសួងផ្សេង, ស្ថាប័នរពាក់ពាល់គ្រប់វិស័យ ក៏ដូចជាអង្គភាពនានាជាមួយគ្នាជាទៀងទាត់ ដើម្បីបង្កើតភាពយោគយល់គ្នាទៅវិញទៅមកនិង

ទុកចិត្តគ្នា[4]។ ក្នុងនាមជាប្រទេសឡាវនិងកម្ពុជា ធ្លាប់ស្ថិតក្រោមអាណានិគមបារាំងដូចគ្នានិងទទួលបានកេរ៍មរដកនៃព្រំដែនជាប្រវត្តិសាស្រ្តរហូតមកដល់ពេលបច្ចុប្បន្ននេះ។ ដូច្នេះ បណ្តាមេដឹកនាំឡាវនិងកម្ពុជានៅក្នុងដំណាកកាលថ្មី បានមើលឃើញពីភាពចាំបាច់ក្នុងការកំណត់ព្រំដែនឱ្យបានត្រឹមត្រូវនិងសមស្របទៅតាមភាពជាក់ស្តែងពិតប្រាកដ ដើម្បីផលប្រយោជន៍ជាតិសម្តៅទៅលើការពង្រីកពង្រឹងសន្តិភាព, ស្ថិរភាពនិងសហប្រតិបិត្តការ រវាងប្រទេសទាំងពីរ ក៏ដូចជាក្នុងកិច្ចសហការអភិវឌ្ឍន៍នៅតំបន់។

[4] សៀវភៅការទូតឡាវ ៧០ ឆ្នាំ ៖ 1945 - 2015, ទំព័រ 184 – 189.

# ជំពូក ទី II
# កិច្ចព្រមព្រៀងរវាងប្រទេសទាំងពីរ
# ក្នុងការចុះត្រួតពិនិត្យ និង បោះបង្គោលព្រំដែន

ក្រោយពីប្រទេសកម្ពុជាទទួលបានជោគជ័យក្នុងការបង្រួបបង្រួមឯកភាពជាតិ ក្រោមរដ្ឋធម្មនុញ្ញ ថ្មី ដោយការដឹកនាំរបស់សម្ដេច នរោត្តម សីហានុ ជាប្រមុខរដ្ឋ, ទំនាក់ទំនងរវាងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រកម្ពុជា ក៏បានឈានចូលដំណាក់កាលថ្មី។ ជាពិសេស នៅឆ្នាំ 1995, រដ្ឋាភិបាលនៃប្រទេសទាំងពីរ បានឯកភាពគ្នាយល់ព្រមអោយមានការផ្លាស់ប្ដូរទស្សនកិច្ចជាផ្លូវការរវាងប្រមុខរដ្ឋនៃប្រទេសទាំងពីរ ដូចជាដំណើរទស្សនកិច្ចជាផ្លូវការព្រះរាជាណាចក្រកម្ពុជារបស់ ឯកឧត្តម នូហាក់ ភូមសាវ៉ាន់ ប្រមូខរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅខែមិថុនា និងការស្ដេចយាងនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវរបស់សម្ដេច នរោត្តម ស៊ីហានុព្រះមហាក្សត្រកម្ពុជាក្នុងខែ វិច្ឆិកា។ នៅក្នុងឱកាសនោះដែរ ឡាវនិងកម្ពុជា បានចុះហត្ថលេខាលើសន្ធិសញ្ញាមិត្តភាពនិងជួយគ្នាទៅវិញទៅមកមួយ ដើម្បីរឹតចំណាងនិងពង្រីកពង្រឹងទំនាក់ទំនងរវាងប្រទេសទាំងពីរ ដើម្បីធានានូវផលប្រយោជន៍គ្នាទៅវិញទៅមក។ ទន្ទឹមនឹងនេះដែរ ភាគីទាំងពីរបានយល់ព្រមអោយបង្កើតគណៈកម្មាធិការសហប្រតិបត្តិការកិច្ចទ្វេភាគីលើវិស័យសេដ្ឋកិច្ច-បច្ចេកទេសនិងវប្បធម៌ ដើម្បីផលប្រយោជន៍រួមគ្នា ក្រោមអធិបតេយ្យភាពរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងបង្កើតគណៈកម្មាធិការចម្រុះព្រំដែនរួម ដើម្បីកំណត់ និងបោះបង្គោលព្រំដែនរួមគ្នា។

ដើម្បីជាសេចក្ដីយោងនៅការអនុវត្តការងារព្រំដែន ក៏ដូចជាការចុះត្រួតពិនិត្យ និងការបោះបង្គោលព្រំដែនរួមគ្នា នៅថ្ងៃទី 22 ខែ វិច្ឆិកា ឆ្នាំ 1995 គណៈប្រតិភូរដ្ឋាភិបាលនៃប្រទេសទាំងពីរបានពិចារណានិងទទួលយកនូវគោលការណ៍ 4 ជាមូលដ្ឋានសម្រាប់ការងារនេះ។ ក្នុងឱកាសកិច្ចប្រជុំលើកដំបូង

របស់គណៈកម្មធិការចម្រុះព្រំដែនរួមឡាវ-កម្ពុជា; កម្ពុជា-ឡាវ ដែនរៀបចំនៅទីក្រុងវៀងច័ន្ទ ក្រោមអធិបតីភាពរបស់អនុរដ្ឋមន្ត្រីក្រសួងការបរទេស និង បានចុះហត្ថលេខាលើកំណត់ហេតុនៃកិច្ចប្រជុំនេះផងដែរ។

ក្រុមអ្នកវិទ្យាសាស្ត្រស្រាវជ្រាវប្រវត្តិសាស្ត្ររបស់វិទ្យាស្ថានវិទ្យាសាស្ត្រសង្គមជាតិ, ក្រៅពីបានបញ្ជាក់ទៅលើព័ត៌មានផ្សេងៗដែលបានរកឃើញ ហើយក៏មានឱកាសជួបសម្ភាស្សជាមួយអាជ្ញាធរជាច្រើននៃគណៈកម្មាធិការចំម្រុះព្រំដែនឡាវ-កម្ពុជា ដើម្បីយល់ដឹងលម្អិត, ច្បាស់លាស់ថែមទៀតផងដែរជាពិសេសអំពីកិច្ចសហការទ្វេភាគីឡាវ - កម្ពុជា ក្នុងកិច្ចព្រមព្រៀងធ្វើការរួមគ្នា។ ក្នុងនេះយើងនឹងរកឃើញសារៈសំខាន់នៃគោលការណ៍ទាំងបួនដែលភាគីទាំងពីរបានឯកភាពជាមួយគ្នាដោយមានខ្លឹមសារលម្អិតដូចខាងក្រោម ៖

1. យោងតាមមូលដ្ឋាននៃការទទួលស្គាល់ព្រំដែនធ្លាប់ជាមួយគ្នា, តំបន់ព្រំដែនដែលធ្លាប់មាននៅពេលស្ថិតក្រោមអាណានិគមបារាំង ដោយផ្អែកទៅលើផែនទីខ្នាត 1/100.000 និងផែនទីពាក់ពាន់ផ្សេងៗទៀតដែលបោះពុម្ពនៅឆ្នាំ 1933 - 1953 ដោយនាយកដ្ឋានផែនទីឥណ្ឌូចិន។
2. ឈរលើមូលដ្ឋាននៅគោលការណ៍ផ្សេងដែលអន្តរជាតិទទួលស្គាល់អំពីការគូសខ្សែព្រំដែន។
3. ឈរលើមូលដ្ឋានដែលមានការពិនិត្យ តំបន់ដែលប្រជាជនបានគ្រប់គ្រងជាក់ស្តែង ហើយមានការបន្តកេរ៍មរដកជាច្រើនជំនាន់មនុស្ស។
4. ឈរលើមូលដ្ឋាននៃសមភាព, សមផរ, សមហេតុផល, យោគយល់ជាមួយគ្នា, ការគោរពសិទ្ធិនិងផលប្រយោជន៍គ្នានិងឯកភាពយ៉ាងពេញលេញ។

ដើម្បីដំណើរការត្រួពិនិត្យ និងបោះបង្គោលព្រំដែននៅលើដីជាក់ស្តែងរួមគ្នា, នៅក្នុងកិច្ចប្រជុំលើកទី II គណៈកម្មការទ្វេភាគីបានប្រារព្ធឡើងនៅរាជធានីភ្នំពេញ ក្នុងអំឡុងពេលថ្ងៃទី 2 - 6 ខែ មិថុនា ឆ្នាំ 1997។ ភាគីទាំងពីរ

បានរួមគ្នាបង្កើតអនុកម្មាការបច្ចេកទេសចម្រុះព្រំដែនឡាវ-កម្ពុជា; កម្ពុជា-ឡាវនិងបានកំណត់សិទ្ធិនិងភារកិច្ចរបស់អនុកម្មាការនេះផងដែល។

ក្នុងឱកាសនេះដែរ គណៈប្រតិភូនៃប្រទេសឡាវនិងកម្ពុជា បានសម្តែងនូវសុច្ឆន្ទៈរបស់ខ្លួនថា ក្រោយពីបានសម្រេចការចុះត្រួតពិនិត្យ និងការបោះបង្គោលព្រំដែនផ្លូវគោកនិងផ្លូវទឹករួចហើយ ប្រទេសទាំងពីរនឹងអនុវត្តបណ្តាជំហានផ្សេងៗតទៅទៀត ដើម្បីឈានទៅបង្កើតសន្ធិសញ្ញាមួយស្តីពីការកំណត់ខ្សែព្រំដែនជាមួយគ្នា។

គួរឱ្យចាប់អារម្មណ៍ជាទីបំផុត យោងប្រតិបត្តិការនិងការចុះត្រួតពិនិត្យលើដីជាក់ស្តែងរបស់អនុគណៈកម្មការបច្ចេកទេសចំម្រុះព្រំដែនឡាវ-កម្ពុជា, កម្ពុជា-ឡាវ បានឯកភាពគ្នាក្នុងកិច្ចប្រជុំលើកទី III របស់គណៈកម្មាការចម្រុះព្រំដែន នៅទីក្រុងវៀងច័ន្ទនៅថ្ងៃទី 12 - 16 ខែ មករា ឆ្នាំ 1998។ ភាគីទាំងពីរបានទទួលយកផែនទីខ្នាត 1/100.000 ចំនួន 11 ផ្ទាំងនិងផែនទីខ្នាត 1/50.000 UTM ដែលបានបោះពុម្ពដោយនាយកដ្ឋានផែនទីអាមេរិកចំនួន 19 ផ្ទាំង។ ភាគីទាំងពីរបានថតចម្លងខ្សែរព្រំដែនពីផែនទីខ្នាត 1/100.000 និងផែនទីដែលពាក់ពាន់ទៅនឹងផែនទីខ្នាត 1/50.000 UTM ដើម្បីប្រៀបធៀបខ្សែព្រំដែនផ្អែកលើមូលដ្ឋាននៃគោលការណ៍ 4 ដែលបានទទួលយករួចហើយនោះ គឺជាការបង្ហាញអោយឃើញនូវប្រតិបត្តិការរួមគ្នា។

យោងទៅតាមការអនុវត្តរបស់អន្តរជាតិ កិច្ចប្រជុំរបស់គណៈកម្មាធិការចម្រុះនោះ នឹងមានការផ្លាស់ប្តូរវេនគ្នារៀបចំនៅប្រទេសនិមួយ។ ដូច្នេះក្នុងកិច្ចប្រជុំលលើកទី IV នៅរាជធានីភ្នំពេញក្នុងកាលពីថ្ងៃទី 17 - 22 ខែ ឧសភា ឆ្នាំ 1999, ភាគីទាំងពីរបានប្រៀបធៀបទិសកំណាត់ព្រំដែន ដែលភាគីនិមួយៗបានគូរ ភាគច្រើនមានលក្ខណៈស្រដៀងគ្នា, លើកលែងតែនៅតំបន់កែងតម៉ារខោយ - អូរតាង៉ាវនិងចំណុចផ្សេងមួយចំនួនទៀត ដោយសារតែភាពគីនិមួយៗបានគូរទិសកំណត់ព្រំដែនខុសគ្នា ដោយបានផ្អែកទៅលើ

ផែនទីពាក់ពាន់នឹងបោះពុម្ពក្នុងអំឡុងឆ្នាំ 1933 ដល់ឆ្នាំ 1953 ដែលសមស្រប នឹងគោលការណ៍ 4 ដែលរៀបរាប់ពីខាងលើនោះ។

ទោះជាយ៉ាងណាក៏ដោយ ភាគីទាំងពីរបានយល់ព្រមចុះត្រួពិនិត្យនៅលើដីជាក់ស្តែងជាមួយគ្នា មុនពេលចុះត្រួតពិនិត្យនៅលើដីជាក់ស្តែងនោះ ភាពគីទាំងពីរដោយមានគណៈអនុកម្មការបច្ចេកទេសចម្រុះនិងបានរៀបចំសេចក្តីព្រាងនូវបែបបទបច្ចេកទេសរួមគ្នា រួចហើយ និងជូនគណៈកម្មាការចំម្រុះព្រំដែនឡាវ-កម្ពុជា, កម្ពុជា-ឡាវ ពិនត្យិនិងសំរេចដើម្បីធ្វើមូលដ្ឋានដោយឡែកដល់ដំណើរការអនុវត្តចុះត្រួពិនិត្យ និងបោះបង្គោលព្រំដែនរួមគ្នានៅពេលអនាគតតទៅ។

## 1. ស្ថានភាពនៃការចុះត្រួពិនិត្យ និង ការបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរ

សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រកម្ពុជា មានខ្សែព្រំដែនជាប់គ្នាប្រហែល 535 គីឡូម៉ែត្រ, ខាងឡាវមានខេត្តពីរគឺ ៖ ខេត្តចាំប៉ាសាក់និងខេត្តអាត់តាពឺ, រីឯខាងកម្ពុជាមានខេត្តបីគឺ ៖ ខេត្តព្រះវិហារ, ខេត្តស្ទឹងត្រែង និងខេត្តរត្តនៈគីរី។

ក្រោយពីបានពិភាក្សានិងទទួលយកនូវបណ្តាគោលការណ៍ ដើម្បីធ្វើជាគន្លឹះយោងមួយហើយក៏បានបង្កើតយន្តការចាំបាច់ផ្សេងៗ អោយបានចាត់តាំងអនុវត្តការងាររួមគ្នា។ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រកម្ពុជា បានចាប់ផ្តើមចុះត្រួតពិនិត្យខ្សែព្រំដែននៅលើដីជាក់ស្តែងរួមគ្នាចាប់ពីឆ្នាំ 2000 នោះមក។

ក្នុងការចុះត្រួពិនិត្យលើដីជាក់ស្តែងនេះ តំបន់ណាមានការឯកភាពគ្នាអំពីការកំណត់ខ្សែព្រំដែន ភាគីទាំងពីរក៏មានការបោះបង្គោលព្រំដែន ភ្លាមគ្លាដំបូងគឺជាបង្គោលព្រំដែនបណ្តោះអាសន្ននិងបន្ទាប់មកភាគីទាំងពីបានឯកភាពគ្នាធ្វើជាបង្គោលព្រំដែនអចិន្ត្រៃយ៍ក្នុងឆ្នាំ 2009។

ក្រោយពីសកម្មភាពចុះត្រួពិនិត្យកំណត់ខ្សែព្រំដែននិងការបោះបង្គោលនៅលើដីជាក់ស្តែងចាប់ពីឆ្នាំ 2000 មកដល់ពេលបច្ចុប្បន្ននេះ ភាគីទាំងពីរបានអនុវត្តសម្រេចដូចតទៅ ៖

- បានសម្រេចការចុះត្រួតពិនិត្យ និងកំណត់ខ្សែព្រំដែននៅលើដីជាក់ស្តែង 465 គីឡូម៉ែត្រ, ស្មើនឹង 87% នៃប្រវែងព្រំដែនទាំងអស់ 535 គីឡូម៉ែត្រ។
- សម្រេចបាននូវការបោះបង្គោលព្រំដែនរួមគ្នាទាំងអស់ចំនួន 126, ដែល មានបង្គោលទោល 116 និងបង្គោលភ្លោះ 10 ។ ក្នុងនេះដែរ ភាគីទាំងពីរបានអនុម័តទទួលយករួចហើយចំនួន 121 បង្គោល នៅក្នុងកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវនិងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការកំណត់ព្រំដែនរវាងប្រទេសទាំងពីរ ចុះថ្ងៃទី 25 ខែ វិច្ឆិកា ឆ្នាំ 2009 ។

## 2. ចំណុចនៅសេសសល់ព្រំដែនរវាងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រកម្ពុជា

ទន្ទឹមនិងជំហ៊ានការចុះត្រួពិនិត្យ និងបោះបង្គោលព្រំដែនរួមគ្នា ដែលភាគីទាំងពីរសំបានសំម្រេច ក្នុងអំឡុងពេលធ្វើបេសកកម្មកាជាមួយគ្នានេះ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រកម្ពុជា នៅមានចំណុចនៅសេសសល់ព្រំដែនមួយចំនួនទៀតដើម្បីដោះស្រាយរួបគ្នា។

ជាដំបូងចំណុចនៅសេសសល់ព្រំដែនមានទាំងអស់ចំនួន 9, ឆ្លងតាមរយៈការចរចាជាមួយគ្នា ភាគីទាំងពីរ បានឯកភាពគ្នានូវគោលការណ៍ស្តីពី ការដំណោះស្រាយចំណុចនៅសេសសល់ព្រំដែននេះចំនួន 7 ចំណុចដូចជា៖

1. **ទីតាំងបង្គោលព្រំដែនលេខ 002 – 003 (ប្រភពទន្លេល្ពៅ) និង បង្គោលលេខ 005 – 023 (តំបន់ទន្លេល្ពៅ)**

– **តំបន់បង្គោលលេខ 002 – 003**

ខ្សែព្រំដែនពីបង្គោលលេខ 002 ទៅដល់បង្គោលលេខ 003 នៅស៊ែទ្បាំភៅ/ទន្លេល្ពៅ គឺកំណត់ខ្សែត្រង់រវាងបញ្ឈរលេខ 522E និង បញ្ឈរលេខ 523E ក្នុងផែនទី UTM ដែលចាប់ផ្ដើមពីចំណុច A (បង្គោលលេខ 002) ដល់ចំណុច B (បង្គោលលេខ 003) នៅចំណុចព្រំដែនភ្ជាប់ជាមួយសាខាគ្លឺះស៊ែទ្បាំភៅ/ទន្លេល្ពៅ ដែលបានបញ្ជាក់ជាបន្ទាត់ក្រហមនៅក្នុងឧប្បសម្ព័ន II[5]។

– **ទីតាំងបង្គោលលេខ 005 – 023**

ភាគីទាំងពីរ មិនទាន់បានព្រមព្រៀងនិងឯកភាពជាមួយគ្នាថា នឹងយោងទៅតាមផែនទី KOMPONG SRALAO Est, ខ្នាត 1/100.000 ដែលភាគីទាំងពីរបានទទួលយក, ទន្លេល្ពៅជាកម្មសិទ្ធិរបស់ឡាវ។ តែភាគីកម្ពុជាស្នើសូមឱ្យភាគីឡាវពិចារណាអនុគ្រោះប្រជាជនកម្ពុជាប្រើប្រាស់ទឹកនៅទន្លេល្ពៅដែលស្ថិតក្រោមអធិបតេយ្យភាពឡាវនិងភាគីឡាវបានពិចារណាអនុគ្រោះនូវភាពមិត្តភ្កិឱ្យប្រជាជនកម្ពុជានៅតំបន់នេះអាចប្រើប្រាស់ទឹកបាន។

2. **បង្គោលព្រំដែនភ្លូសលេខ 029 និង 030**

បង្គោលព្រំដែនភ្លូសលេខ 029 និង 030 នេះភាគីទាំងពីរបានឯកភាពជាមួយគ្នានិងបានព្រមព្រៀងគ្នាបោះបង្គោលព្រំដែននៅលើដីជាក់ស្តែង

[5] អនុស្សារណៈរវាងឧបនាយករដ្ឋមន្ត្រី, រស្តមន្ត្រី ក្រសួង ការបរទេសនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងឧបនាយករដ្ឋមន្ត្រី, រស្តមន្ត្រី ក្រសួង ការបរទេសនិងសហការអន្តរជាតិនៃព្រះរាជណាចក្រកម្ពុជា, ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៩, ចំណុចទី ២។

បានរួចហើយ។ បច្ចុប្បន្ននេះ ភាគីទាំងពីរនឹងរៀបចំការវាស់ចម្ងាយពីបង្គោលព្រំដែនខាងនិមួយៗជាសាថ្មីម្តងទៀត ដោយសារតែការវាស់នៅកន្លងមកមិនទាន់ត្រឹមត្រូវទេ។

3. **ទីទាំងនឹងមានការបោះបង្គោលព្រំដែនលេខ 031 - 031/A (វើនខាម)**

ព្រំដែនរវាងបង្គោលលេខ 031/1 និងបង្គោលលេខ 031 នៅក្នុងតំបន់វើនខាម - អូរស្វាយ គឺជាខ្សែត្រង់មួយដែលចាប់ផ្តើមពីបង្គោលលេខ 031/1 ដល់ចំណុចលេខ 031/A ហើយចាប់ពីចំណុចនេះតទៅព្រំដែននៅតែបន្តទៅដល់បង្គោលលេខ 031 នៅច្រាំងទន្លេម៉េគង្គ ហើយឆ្លងតាមរយៈ ដើមឈើធំមួយដែលហៅថា "កកដឿ"(ឈ្មោះជាភាសាឡាវ) ឬហៅថា "ដើមល្វា" (ក្នុងភាសាខ្មែរ) ដែលបានបញ្ជាក់នៅក្នុងសារបណ្ណទី II[6]។

4. **ទីតាំងបង្គោលព្រំដែនលេខ 032 - 032/6 (ផ្លូវចុះវើនខាម)**

ឧបនាយករដ្ឋមន្ត្រីឡាវនិងឧបនាយករដ្ឋមន្ត្រីកម្ពុជា បានឯកភាពគ្នាក្នុងឱកាសជួបគ្នានៃកិច្ចប្រជុំថ្ងៃទី 03 ខែ កុម្ភៈ ឆ្នាំ 2012 ហើយបានកំណត់ខ្សែព្រំដែននៅតំបន់នេះជាខ្សែត្រង់មួយចាប់ពីបង្គោលព្រំដែនលេខ 032 ដល់បង្គោលលេខ 032/6។

យោងជាមូលដ្ឋាននៃការព្រមព្រៀងគ្នាខាងលើនេះ ក្រុមបច្ចេកទេសចំម្រុះព្រំដែនរបស់ភាគីទាំងពីរក៏បានរួមគ្នាបោះបង្គោលព្រំដែនក្នុងតំបន់នេះសម្រេចចំនួន 5 (បង្គោលព្រំដែនលេខ 032/1 ដល់លេខ 032/5)។

5. **ទីតាំងតំបន់នឹងការបោះបង្គោលព្រំដែន លេខ 033 - 033/3(ផ្លូវដុងកាឡ, លេខ 13/7)**

---

[6] កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវនិងរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា, ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩, មាត្រា ៣។

តំបន់ព្រំដែនដុងកាឡ តាមផ្លូវជាតិលេខ 13 (ឡាវ) និងលេខ 7 (កម្ពុជា) មានប្រវែងប្រហែល 7,85 គីឡូម៉ែត្រ ភាគីទាំងពីរបានយល់ព្រមគ្នាកំណត់ខ្សែព្រំដែនឆ្ងាយពីចំណុចកណ្តាលនៃផ្លូវនេះ 11,50 ម៉ែត្រ ដោយចាប់ផ្តើមពីទីទាំងបោះបង្គោលព្រំដែនលេខ 033 ដល់ទីទាំង 033/3 ដែលបានបញ្ជាក់នៅក្នុងមាតិកា I [7]។

6. **តំបន់ភូមិ ណាំចាំប៉ា**

ភាគីទាំងពីរបានព្រមព្រៀងគ្នានឹងដោះស្រាយបញ្ហាកម្មសិទ្ធិលើភាពជាម្ចាស់នូវភូមិ ណាំចាំប៉ា តាមផែនទី S.G.I. ខ្នាត 1/100000[8]។

7. **តំបន់អូរស្មុត - អូរក្រលាង**

ភាគីទាំងពីរបានព្រមព្រៀងគ្នានឹងដោះស្រាយបញ្ហានៅតំបន់ហួយក្រលាង/អូរក្រលាង ដោយទទួនស្គាល់អូរនេះជារបស់កម្ពុជាតាមផែន ទី S.G.I. ខ្នាត 1/100000[9]។

តាមទស្សនៈរបស់អ្នកស្រាវជ្រាវប្រវត្តិសាស្រ្តការទំនាក់ទំនងទ្វេភាគីឡាវ - កម្ពុជា នោះគឺបានយល់ថា ភាគីទាំងពីរឡាវនិងកម្ពុជា សុទ្ធតែបានខិតខំព្យាយាមយ៉ាងសកម្មនិងបានឯកភាពគ្នាពិនិត្យនិងសំម្រេចនូវការដោះស្រាយបញ្ហាព្រំដែនលើដីជាក់ស្តែងបានជាច្រើននិងមានចំហ៊ានឈានទៅមុខច្រើនដែរ  ប៉ុន្តែនៅមានចំណុចនៅសេសសល់មួយចំនួនដែលភាគីទាំងពីរត្រូវ

---

[7] កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវនិងរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា, ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩, មាត្រា ២.

[8] កំណត់ហេតុ រវាងអនុរដ្ឋមន្ត្រី ក្រសួង ការបរទេសនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងអនុរដ្ឋមន្ត្រី ក្រសួង ការបរទេសនិងសហការអន្តរជាតិនៃព្រះរាជណាចក្រកម្ពុជា, ចុះថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០០៨, ចំណុចទី ៣។

[9] កំណត់ហេតុរវាងអនុរដ្ឋមន្ត្រី ក្រសួង ការបរទេសនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងអនុរដ្ឋមន្ត្រី ក្រសួង ការបរទេសនិងសហការអន្តរជាតិនៃព្រះរាជណាចក្រកម្ពុជា, ចុះថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០០៨, ចំណុចទី៤។

តែរួមគ្នាបន្តដោះស្រាយដូចជា ៖ នៅតំបន់ទន្លេស៊េកុង និងតំបន់កែងតម៉រខោយ - អូរតង៉ាវ។

តំបន់នៅសេសសល់ទាំងពីរនេះស្ថិតនៅក្នុងចំណោម 13% របស់ព្រំប្រទល់ដែលភាគីទាំងពីរមិនទាន់ចុះត្រួពិនិត្យនៅលើដីជាក់ស្តែងរួមគ្នាទេ ចាប់ពីបង្គោលព្រំដែនលេខ 078 តាមបណ្តោយទន្លេស៊េកុង ឡើងទៅកាន់តំបន់កែងតម៉រខោយ - អូរតង៉ាវ (ដល់បង្គោលព្រំដែនលេខ 099) ជាតំបន់ដែលមានស្ថានភាពដូចពេលបច្ចុប្បន្ន។

ក្រុមអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រ បានតែងតាំងក្រុមមួយចុះទៅពិនិត្យមើលទៅលើដីជាក់ស្តែងនិង ស្វែងរកស្ថានភាពពិតប្រាកដជាមួយប្រជាជនដែលរស់នៅក្នុងតំបន់ទាំងនោះទើបបានជ្រាបថា ៖

តំបន់កែងតម៉រខោយ - អូរតង៉ាវ ជាបតំបន់មួយដែលភាគីទាំងពីរនៅតែមានគំនិតទស្សនៈខុសគ្នាអំពីការគូសកំណត់ខ្សែព្រំដែននៅឡើយទេ ដោយសារតែភាគីនិមួយៗបានអះអាងលើឯកសារនិងផែនទីដែលផ្តល់ពត៌មានខុសប្រែកពីគ្នា។ ទោះជាយ៉ាងណាក៏ដោយ បើផ្អែកលើភាពជាក់ស្តែងនៅចំនាន់បារាំងគ្រប់គ្រង នៅលើត្រើយខាងឆ្វេងដីនៃទន្លេស៊េកុង, ខាងអូរកឿ, អូរដាក់ឡាវ ហើយប្រជាជនក្នុងតំបន់បានប្រាប់អោយដឹងថា នេះគឺជាតំបន់រកស៊ីប្រកបមុខរបររបស់ប្រជាជនឡាវនៅភូមិហាត់យៃ (ភូមិហាត់អ៊ូដំសៃ), ភូមិសែនកែវ ដែលនាំគ្នាទៅធ្វើចំម្ការ, ធ្វើស្រែ, នេសាទត្រីនិងប្រមាញ់សត្វ ហើយបច្ចុប្បន្ននេះ យើងនៅតែឃើញស្នាមនៃស្រែចាស់, ចម្ការចាស់ របស់ប្រជាជននៅកាលសម័យនោះ។

ព្រំដែនរវាងប្រទេសឡាវនិងកម្ពុជា ពេលនោះបានជ្រើសរើសយកអូរដាក់ឡាវ( ពាក្យថា“ដាក់ ឡាវ” គឺជាពាក្យនៃភាសាជនជាតិ ឡះវ៉ៃ មានន័យថា “ទឹកឡាវ”) ហើយអូរដាក់ឡាវនេះមានន័យថា “ទន្លេទឹកឡាវ”។

នៅក្នុងកាលសម័យព្រះរាជណាចក្រឡាវ កងកម្លាំងយោធាឡាវមានការត្រួតពិនិត្យលើតំបន់អូរកឿនិងអូរដាក់ឡាវ ដើម្បីការពារព្រំដែនតាមបញ្ហារបស់មេបញ្ជាការការពារទឹកដី។ អាជ្ញាធរនិងអភិបាលមូលដ្ឋានរបស់ប្រទេសទាំងពីរ ឡាវ - កម្ពុជា បានទទួនស្គាល់និងចាត់ទុកថា នេះជាតំបន់បែងចែកនៃអធិបតីយ្យភាពប្រទេសទាំងពីរ។ ក្រៅពីនេះ តំបន់កែងតម៉រខោយ - អូរតង៉ាវ នៅឃើញមានស្នាមយន្តហោះកងទ័ពអាមេរិកធ្លាក់និងមានរណ្តៅគ្រាប់បែកចាស់លេចដានក្នុងតំបន់នេះ។ នៅក្នុងសម័យសង្គ្រាម មានយន្តហោះកងទ័ពអាមេរិកបានធ្លាប់ទម្លាក់គ្រាប់បែកក្នុងបរិវេណនេះ។ ដោយសារអាមេរិកចាត់ទុកជាទឹកដីរបស់ឡាវ (ប្រសិនបើតំបន់នេះជាកម្មសិទ្ធិនៃប្រទេសកម្ពុជាកងទ័ពអាមេរិកនឹងមិនអាចទម្លាក់គ្រាប់បែកនៅទីនេះទេ ពីពោះអាមេរិកមានការគាំទ្ររដ្ឋាភិបាលរបស់ឧត្តមសេនីយ៍ លន់ នល់)។ ចំពោះបរិវេណយន្តហោះធ្លាក់នោះ នៅពេលបច្ចុប្បន្ននេះប្រជាជនឡាវហៅតំបន់នេះថា "ភូយន្តតុក" (ភ្នំធ្លាក់យន្តហោះ)។ មួយទៀត, ក្នុងអំរុងពេល ខ្មែរក្រហមកាន់អំណាចនិងដំណើរការប្រល្បៃពុជសាស្រនៅកម្ពុជា, ប្រជាពលរដ្ឋកម្ពុជា ជាច្រើនបានភៀសខ្លួនមករស់នៅតំបន់កែងតម៉រខោយ - អូរតង៉ាវនេះ ហើយពួកខ្មែរក្រហមមិនបានតាមមកបង្ក្រាបគេបានទេ ពីពោះគេទទួនស្គាល់ថា បរិវេណនេះគឺជាដែនដីរបស់ប្រទេសឡាវ។

មួយទៀតដែលបញ្ជាក់ពីការគ្រប់គ្រងរបស់ប្រជាជនឡាវ, បើយោងតាមការសំភាសន៍អ្នកចាស់ទុំនៅតាមស្រុកនេះបានដឹងថា ភូមិតង៉ាវ នៅទីនេះមានភូមិពីរគឺ ៖ ភូមិតង៉ាវក្រោមនិងភូមិតង៉ាវលើ ដែលស្ថិតនៅត្រើយខាងស្តាំទន្លេសេកុង(តាមបង្ហូរទឹក) ដែលមានជនជាតិឡាវរស់នៅជាច្រើន ពួកគេមកតាំងទីលំនៅតាំងពីជំនាន់បារាំងគ្រប់គ្រង។ អំពីភូមិតង៉ាវលើមានទីតាំងនៅត្រើយខាងឆ្វេងគឺជាភូមិតូចមួយមានប្រជាជនរស់នៅតិចប្រហែល 10 គ្រួសារ ទាំងអស់ជាជនជាតិឡៈវ៉ៃ និងជនជាតិស៊ុ ហើយជាភូមិផ្លូវទីតាំងញឹក

ញាប់។ ចាប់តាំងពីឆ្នាំ 1968 រហូតដល់ឥឡូវនេះ ប្រជាជននៅក្នុងភូមិនេះហាក់ដូចជាមានការផ្លាស់ភូមិទៅនៅភូមិហាតសាយស៊ុង។ មូលហេតុការផ្លាស់ទីដោយសារកើតជំងឺរាគរូសធ្ងន់ធ្ងរ។ នៅពេលបច្ចុប្បន្ននេះ មានការរកឃើញដាននៃការតាំងទីលំនៅនិងជីវៈភាពរស់នៅរបស់ប្រជាជនឡាវ ដូចជាដើមស្វាយ, ខ្នុន, ស្នូរចម្ការ, ដានស្រែ, ឆ្នាំងបែកនិងផ្លូវចុះកំពង់ទឹក។ និយាយរួម, ភូមិតង៉ាវទាំងពីរដែលពោលខាងលើនោះ នៅក្នុងស្រុក ស្នាមសែ ខេត្តអាត់តាពឺ ចាប់តាំងពីជំនាន់បារាំងគ្រប់គ្រងមកម្ល៉េះ, សម័យព្រះរាជាណាចក្រឡាវនិងនៅពេលក្រោមរបបសាធារណរដ្ឋប្រជាធិបតេយ្យឡាវ រហូតដល់ឥឡូវនេះ។ ប៉ុន្តែក្នុងបច្ចុប្បន្ននេះ កងទ័ពកម្ពុជាបានបំផ្លាញចោលអស់និងបានផ្លាស់ប្តូរទិសភាពធម្មជាតិនិងបរិស្ថានក្នុងបរិវេណនេះទាំងស្រុង។

នៅមានអតីតមន្ត្រីយោធានិងទាហ៊ានដែលធ្លាប់បំពេញបេសកកម្មនៅបរិវេណនេះ បានអោយដឹងថា ក្រោយពីបង្កើតរបបសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ពីឆ្នាំ 1975 មកនេះ តំបន់កែងតម៉រខោយ - អូរតង៉ាវ ស្ថិតនៅក្រោមការត្រួតត្រា ជានិតរបស់វិរសេនាតូច 21 របស់ស្នងការយោធាខេត្តអាត់តាពឺ ដោយបានដាក់ជំរំរស់នៅនៅចំណុចផ្សេងៗដូចខាងក្រោម៖

- ឆ្នាំ 1992 មានទីតាំងនៅខាងឆ្វេងទន្លេសេកុង នៅអូរដាកឡាវ;
- ឆ្នាំ 1993 - 1994 បានផ្លាស់ប្តូរទីតាំងពីអូរដាកឡាវមកដាក់នៅតំបន់មាត់អូរតង៉ាវ;
- ឆ្នាំ 1996 – 1997 បានផ្លាស់ប្តូរពីតំបន់មាត់អូរតង៉ាវមកតាំងនៅបរិវេណអូរអាឡៃ។

សកម្មភាពទាំងនេះនៃស្នងការយោធាខេត្ត អាត់តាពឺ របស់ភាគីឡាវនេះ ភាគីកម្ពុជា ក៏បានទទួលស្គាល់និងមិនដែលមានការចោទប្រកាន់ឬមានទំនាស់និងគ្នាតែយ៉ាងណាឡើយទេ។

យោងតាមកំណត់ហេតុនៃការពិភាក្សាចរចាររវាងអភិបាលស្រុក ស្នាមសែ ខេត្ត អាត់តាពឺ និងស្រុក សែនប៉ាង ខេត្ត ស្ទឹងត្រែង ចុះថ្ងៃទី 27 ខែ ឧសភា ឆ្នាំ 1990, អភិបាលស្រុក សែនប៉ាង បានស្នើការទទួលខុសត្រូវនៅតំបន់អូរគៀ ចំពោះភាគខាងកើតបានយល់ព្រមអោយភាគីឡាវត្រួតពិនិត្យ។ អភិបាលស្រុកទាំងពីរបានព្រមព្រៀងគ្នាបន្តអនុវត្តនូវកំណត់ហេតុនៃគណៈប្រតិភូស្រុកទាំងពីរ ដែលបានជួបប្រជុំគ្នារួចទៅហើយនោះ ដើម្បីរក្សារការពារសន្តិសុខសាធារណៈនៅតំប់នចន្លោះរវាងស្រុក ស្នាមសែ និងស្រុក សែនប៉ាង[10]។ នៅក្នុងកិច្ចប្រជុំពីរលើកនៅឆ្នាំ 1995 ស្រុកទាំងពីរនៅតែបន្តបែងចែកតំបន់រក្សាការបែងចែកតំបន់គ្រប់គ្រងនេះ[11]។

## 3. កិច្ចព្រមព្រៀងគ្នា របស់ភាគីទាំងពីរអំពីតំបន់នៅសេសសល់នៅកែងតម៉ររខោយ -អូរតង៉ាវ

អាជ្ញាធរមូលដ្ឋានអោយដឹងថែមទៀតថា ភាគីទាំងពីរបានឯកភាពគ្នាថាតំបន់នេះគឺជាតំបន់នៅសេសសល់មិត្តភាព និងហាមឃាត់មិនអោយមានការធ្វើកិច្ចការណាទាំងអស់ទេ, គួរតែថែរក្សាទុកស្ថានភាពដដែលក្នុងតំបន់នេះរហូតដល់ពេលណាសម្រេចការចុះត្រួពិនិត្យ និងបោះបង្គោលកំណត់ព្រំដែនជាស្ថាពរ។

តំបន់ដែលភាគីទាំងពីរមិនទាន់រួមគ្នាចុះត្រួពិនិត្យដូចជា តំបន់កែងតម៉ររខោយ - អូរតង៉ាវ គណៈកម្មការចំម្រុះព្រំដែននៃប្រទេសទាំងពីរបានឯកភាពគ្នានឹងរក្សាស្ថានភាពនៅបរិវេណទាំងនោះអោយមានស្ថានភាពដូចដើមដោយហាមឃាត់អភិបាលមូលដ្ឋាននៃប្រទេសនិមួយនិងអាជ្ញាធរពាក់ពន្ធ័

---

[10] កំណត់ហេតុរបស់ស្រុកសែងបាង, កម្ពុជា និង ស្រុកសណានសែ, ឡាវ ចុះថ្ងៃទី 23 ខែ វិច្ឆិកា ឆ្នាំ 1992, ខទី2។

[11] កំណត់ហេតុចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៥, ။ ចំណុចទី ២ និងចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៥, ។ ចំណុចទី ២។

របស់ខ្លួនធ្វើកិច្ចការក៏សាងអ្វីៗទាំងអស់ ដែលអាចធ្វើអោយមានការផ្លាស់ប្តូរស្ថានភាពនៅបរិវេណព្រំដែន[12]។ យោងទៅតាមកិច្ចព្រមព្រៀងនេះ រដ្ឋាភិបាលក៏បានផ្សព្វផ្សាយអោយប្រជាជននៅមូលដ្ឋានបានជ្រួតជ្រាបយល់ដឹង ប្រជាជនក៏បានអនុវត្តតាម ដោយសារតែជាកិច្ចព្រមព្រៀងនៃគណៈប្រតិភូទាំងពីរ។ អំពីបញ្ហានេះ ភាគីទាំងពីរបានអះអាងជាសារថ្មីម្តងទៀតនូវបំណងប្រាថ្នានេះ។ ក្នុងឱកាសបើកកិច្ចប្រជុំលើកបន្ទាប់មកនេះ[13]។ ជាពិសេស នៅតំបន់កែងតម៉រខោយ - អូរតង៉ាវ ដែលភាគីទាំងពីរបានព្រមព្រៀង និងឯកភាពគ្នានូវការកំណត់ខ្សែព្រំដែន និងហាមឃាត់យ៉ាងច្បាស់ថា ៖ "ភាគីទាំងពីរបានព្រមព្រៀងគ្នារក្សាស្ថានភាពដូចដើម ដោយគ្មានការសាងសង់អ្វីទាំងអស់ទេដែលអាចនាំឱ្យមានការផ្លាស់ប្តូរស្ថានភាពនៅបរិវេណព្រំដែននោះ។ ក្រៅពីនេះ ភាគីទាំងពីរបានជំរុញឱ្យខេត្ត អាត់តាពឺ និងខេត្ត ស្ទឹងត្រែង បន្តសហការជាមួយគ្នាត្រួតពិនិត្យរួមគ្នា រហូតដល់ពេលណាភាគីទាំងពីរនឹងបានសម្រេចនូវការបោះបង្គោលព្រំដែននៅក្នុងបរិវេណនេះ"[14]។ ចំពោះកិច្ចព្រមព្រៀជាមួយគ្នានៃភាគីទាំងពីរក្នុងពេលកន្លងមក ជាពិសេសនៅការអនុវត្តជាក់ស្តែង អាជ្ញាធរកម្ពុជា សុទ្ធតែបានទទួលស្គាល់ ហើយចាត់ទុកថា តំបន់កែងតម៉រខោយ-អូរតង៉ាវ ជាតំបន់នៅសេសសល់ ជាតំបន់ដែលភាគីទាំងពីរមិនទាន់បានគូសកំណត់ខ្សាយព្រំដែន និងហាមធ្វើសកម្មភាពក្នុងតំបន់នេះ, ភាគីទាំងពីរក៏បានពិភាក្សាគ្នា។ ឧទាហរណ៍ដែលបង្ហាញអោយឃើញឥរិយាបថនេះគឺក្នុងករណីភាគីកម្ពុជាបានជូនដំណឹងជាផ្លូវការឱ្យភាគីឡាវជ្រួតជ្រាបគោល

[12] កំណត់ហេតុកិច្ចប្រជុំនៃគណៈកម្មាធិការព្រំដែនឡាវ - កម្ពុជា, កម្ពុជា - ឡាវ លើកទី ២, ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ១៩៩៧, ខទី ៨(៥)។

[13] កំណត់ហេតុកិច្ចប្រជុំវិសាមញ្ញគណៈកម្មាការព្រំដែនឡាវ - កម្ពុជា, កម្ពុជា - ឡាវ, ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ ២០០៦ ចំណុចទី ១១។

[14] កំណត់ហេតុកិច្ចប្រជុំវិសាមញ្ញគណៈកម្មាការព្រំដែនឡាវ - កម្ពុជា, កម្ពុជា - ឡាវ, ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤, ខទី ៦។

បំណងនៃកងទ័ពអាមេរិកចង់ចូលមកទាញយកឆ្អឹងរបស់យោធាអាមេរិកដែលបាត់បង់ក្នុងសម័យសង្គ្រាមឥណ្ឌូចិន ក្រោយពីបានដឹងថាយន្តហោះពួកគេធ្លាក់នៅតំបន់នេះ[15]។

នៅពេលពិនិត្យមើលកិច្ចសហប្រតិបត្តិការនៃភាគីទាំងពីរ ក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ ក្រុមអ្នកស្រាវជ្រាវវិទ្យាសាស្ត្រយើងបានឃើញថា ភាគីឡាវមានការគោរពគ្រប់ពេលវេលា, ប្រកាន់និងអនុវត្តយ៉ាងតឹងរឹងនូវកិច្ចព្រំព្រៀងជានិច្ច។ ដូចជាករណីភាគីកម្ពុជាបានចោទប្រកាន់ភាគីឡាវនិងស្នើអោយដោះចេញ, បញ្ឈប់ការចិញ្ចឹមសត្វនិងសើររើចេញផ្ទះសម្បែងរបស់ប្រជាជនឡាវនៅតំបន់អូរតង៉ាវ តាមលិខិតរបស់សម្តេចតេជោ ហ៊ុន សែន ចុះថ្ងៃទី 24 ខែ មក្ករា ឆ្នាំ 2013 ជូនឯកឧត្តម ជូមម៉ាលី សៃញ៉ាសន់ ប្រមុខរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។ ពេលនោះភាគីឡាវបានបង្ហាញនូវសេចក្តីស្មោះត្រង់និងសុឆន្ទៈដ៏ល្អ ដោយបានកំទេចកំទីជម្រកសត្វនៅបរិវេណនោះចេញទាំងអស់ពីបរិវេណនេះ ព្រមទាំងបានផ្តល់ដំណឹងអោយភាគីកម្ពុជាបានជ្រួតជ្រាប។ យោងតាមលិខិតរបស់ ឯកឧត្តម ថង់លុន ស៊ីស៊ុលិត ដែលពីមុនជាឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួង ការបរទេសនៃសាធារណៈរដ្ឋប្រជាធិបតិយ្យប្រជាមានិតឡាវ ដែលជូនទៅ ឯកឧត្តម ហរ ណាមហុង, ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួង ការបរទេសនិងសហការរអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី 20 ខែ កក្កដា ឆ្នាំ 2013 បានសរសេរថា *“ដំណោះស្រាយរបស់ភាគីឡាវនេះនឹងមិនប៉ះពាល់ដល់អាកប្បកិរិយានៃភាគីនិមួយលើផ្នែកច្បាប់និងប្រវត្តិសាស្ត្រទេ ដើម្បីអះអាងក្នុងការដំណោះ*

---

[15]លិខិតក្រសួង ការបរទេសនិងសហការអន្តរជាតិនៃព្រះរាចណាចក្រកម្ពុជា, ស្លាប់លេខទី ១៦០៩ MFA-IC/LC4, ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦, លេខទី ២៧៧៨ MFA-IC/LC4, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦។

*ស្រាយចំណុចនៅសេសសល់នៅកែងតម៉ រខោយ - អូរតង៉ាវ ជាមួយគ្នានៅពេលអនាគត"។*

បញ្ហាដែលត្រូវចាប់បារម្ភនៃទំនាក់ទំនងរវាងប្រទេសទាំងពីរនោះគឺ ភាគីកម្ពុជាបានអនុវត្តផ្ទុយនឹងកិច្ចព្រមព្រៀងជាមួយភាគីឡាវហើយថា តំបន់កែងតម៉ រខោយ - អូរតង៉ាវ គឺជាតំបន់នៅសេសសល់និងហាមមិនអោយធ្វើសកម្មភាពអ្វីនៅក្នុងបរិវេណនេះទេ។ ប៉ុន្តែ ក្រោយមកភាគីកម្ពុជាមិនគោរព, មិនអនុវត្តទេនិងបានល្មើសកិច្ចព្រមព្រៀងគ្នានេះគឺជាមូលហេតុនាំអោយកើតមានស្ថានភាពតានតឹងតាមនៅតំបន់ព្រំដែន។

## 4. ព្រឹត្តិការណ៍ដែលកើតឡើងនៅតាមតំបន់ព្រំដែននិងការខិតខំដោះស្រាយតាមរយៈការទូតនិងយន្តការសម្របសម្រួលនៃភាគីទាំងពីរ

បើយោងតាមព័តមានពីមន្ត្រីពាក់ពាល់, បញ្ហានៃភាពតានតឹងនៅតំបន់កែងតម៉ រខោយ - អូរតង៉ាវ ដោយសារតែការសាងសង់ផ្លូវថ្នល់របស់ភាគីកម្ពុជាបានរំកិនចូលជ្រៅទៅតំបន់ព្រំដែនដែលមិនទាន់សម្រេចនៃការចុះត្រួពិនិត្យនៅលើដីជាក់ស្តែងដែលជាតំបន់នៅសេសសល់កែងតម៉ រខោយ - អូរតង៉ាវ។

ចាប់ពីដើមខែ កុម្ភៈ ឆ្នាំ 2017, ក្រុមវិស្វកម្មយោធា ក្រសួង ការពារជាតិកម្ពុជា បានកសាងផ្លូវថ្នល់តាមបណ្តោយទន្លេសេកងរំកិនចូលទៅក្នុងតំបន់កែងតម៉ រខោយ - អូរតង៉ាវ ហើយផ្លូវថ្នល់ដែលបានកសាង ក៏មានការដាក់កងកម្លាំងពង្រាយទន្ទឹមនៅចំណុចមួយៗទៀតផងដែរ។ ទង្វើបែបនេះគឺជា ការរំលោភលើកិច្ចព្រមព្រៀងនៃប្រទេសទាំងពីរ ដែលហាមឃាត់មិនឱ្យមានសាងសង់ឬឈូសឆាយនៅតំបន់ព្រំដែនដែលភាគីទាំងពីរមិនទាន់សម្រេចការចុះត្រួតពិ និត្យរួមគ្នានោះទេ។ ដូច្នេះ ភាគីឡាវទើបបានចោទប្រកាន់ ដើម្បីដោះស្រាយយ៉ាងសន្តិវិធីនិងបានផ្ញើលិខិតមួយទៅកាន់ភាគីកម្ពុជានិងស្នើអោយកម្ពុជាបញ្ឈប់ភ្លាមការសាងសង់ផ្លូវថ្នល់ជាច្រើនដងនិងច្រើនកម្រិត ទាំងថ្នាកដ្ឋានអំណាចមូលដ្ឋាននិងថ្នាក់ជាតិ។

ឯកឧត្តមនាយករដ្ឋមន្ត្រីនៃសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានផ្ញើតឱកាសជួបពិភាក្សារការងារជាមួយលោកនាយករដ្ឋមន្ត្រីនៃព្រះរាជណាចក្រកម្ពុជា នៅថ្ងៃទី 10 ខែ ឧសភា ឆ្នាំ 2017 ដើម្បីពិភាក្សាអំពីការដោះស្រាយបញ្ហាក្នុងឱកាសធ្វើដំណើរចូលរួមវេទិកាសេដ្ឋកិច្ចពិភពលោក (World Economic Forum) នៅរាជធានីភ្នំពេញ។ ក្នុងពេលជាមួយគ្នានេះដែរ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានយល់ព្រមបញ្ឈប់ការសាងសង់ផ្លូវថ្នល់និងអោយមានការចុះត្រួតពិនិត្យ នៅលើដីជាក់ស្តែងជាមួយគ្នានៃគណៈកម្មការចំម្រុះព្រំដែន។ បន្ទាប់ពីការជួបពិភាក្សានោះ ភាគីកម្ពុជាមិនបានអនុវត្តតាមកិច្ចព្រមព្រៀងនេះទេ, ក្រុមវិស្វកម្មយោធាកម្ពុជានៅតែបន្តសាងសង់ផ្លូវថ្នល់រហូតឈានទៅដល់តំបន់អូរអាឡៃ នៅក្នុងតំបន់កែងតម៉ខោយ - អូរតង៉ាវ ដែលជាតំបន់ចម្រូងចម្រាស់ នេះជាការរំលោភនៃកិច្ចព្រមព្រៀងរបស់អ្នកដឹកនាំប្រទេសទាំងពីរ។ ចំពោះសភាពការណ៍បែបនេះ ភាគីឡាវទើបដាក់កងកម្លាំងត្រួតពិនិត្យនៅតំបន់អូរអាឡៃ ដើម្បីចោទប្រកាន់និងទប់ស្កាត់មិនអោយភាគីកម្ពុជាបន្តការឈូសឆាយផ្លូវថ្នល់ និងញ្ឈប់ការកសាងទាំងអស់នេះ។

ក្រោយមកទៀត កាលពិថ្ងៃទី 5 - 6 ខែ កក្កដា ឆ្នាំ 2017 ភាគីទាំងពីរបានបន្ទូនគណៈកម្មការចំម្រុះព្រំដែននៃប្រទេសទាំងពីរ ចុះត្រួតពិនិត្យនៅលើដីជាក់ស្តែង ប៉ុន្តែមិនអាចដោះស្រាយបញ្ហាបានទេ។

ដោយបន្តសកម្មភាពនៃកងកម្លាំងយោធារបស់ភាគីឡាវ ដើម្បីទប់ស្កាត់ភាគីកម្ពុជាដែលនៅតែបន្តកសាងផ្លូវថ្នល់នោះទើបបណ្តាលឱ្យភាគីកម្ពុជាចោទប្រកាន់ថា ភាគីឡាវឈ្លានពានអធិបតេយ្យភាពរបស់កម្ពុជានិងបានបំពេញបន្ថែមកងកម្លាំងប្រចាំការនិងទើបបង្កឱ្យមានភាពតានតឹងនៅក្នុងតំបន់នេះ។

នៅថ្ងៃទី 11 ខែ សីហា ឆ្នាំ 2017 ភាគីកម្ពុជា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសតាម រយៈប្រព័ន្ធផ្សព្វផ្សាយនិងតាមរយៈហ្វេសប៊ុក (Facebook) របស់ខ្លួន បានអំពាវនាវអោយរដ្ឋាភិបាលឡាវត្រូវតែដក់កង កម្លាំងយោធាទាំងអស់ចេញពីអធិបតេយ្យភាពរបស់កម្ពុជាក្នុងរយៈពេល 6 ថ្ងៃ (ថ្ងៃទី 17 ខែ សីហា ឆ្នាំ 2017) បើមិនដូច្នេះទេនឹងប្រតិបត្តិការដោយកង កម្លាំងយោធា។ ក្នុងថ្ងៃតែមួយនេះដែរ ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកនិងអន្តរ ជាតិបានផ្សព្វផ្សាយបង្ហាញភាពកងទ័ពកម្ពុជាផ្លាស់ទី ដើម្បីឆ្ពោះទៅកាន់ព្រំ ដែនផ្ទាប់ជាមួយឡាវហើយអះអាងថា ដើម្បីបន្តេញយោធាឡាវចេញពីតំបន់ អូរតង៉ាវ,,,,,ដែលភាគីកម្ពុជាបានអះអាងថា ជាអធិបតេយ្យភាពរបស់កម្ពុជា។

មុននេះគឺនៅថ្ងៃទី 7 ខែ សីហា ឆ្នាំ 2017, ក្រសួង ការបរទេសឡាវ បានទទួលលិខិតមួយចុះថ្ងៃទី 2 ខែ សីហា ឆ្នាំ 2017 របស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ជូនមកកាន់នាយករដ្ឋមន្ត្រី ថង់លុន ស៊ីស៊ុលិត នៃសាធារណរដ្ឋ ប្រជាធិបតេយ្យប្រជាមានិត្យឡាវតាមរយៈស្ថានទូតកម្ពុជាប្រចាំឡាវ ដើម្បីស្នើ អោយភាគិឡាវដក់កងទ័ពចេញពីបរិវេណអូរអាឡៃដែលកម្ពុជាអះអាង ថាជា អធិបតេយ្យភាពរបស់ខ្លួន និងសូមភាគីឡាវទទួនយកនូវការសម្នើរបស់ភាគី កម្ពុជា ក្នុងការដោះស្រាយនៅចំណុច 4 ដែលមានកិច្ចព្រមព្រាងជាមួយគ្នា ហើយនោះជាសារថ្មីម្តងទៀត។ ព្រឹកថ្ងៃទី 12 ខែ សីហា ឆ្នាំ 2017, នាយករដ្ឋ មន្ត្រី ហ៊ុន សែន បានធ្វើដំណើមកកាន់ទីក្រុងវៀងច័ន្ទ ដើម្បីជួបសំណែះសំ ណាលជាមួយនាយករដ្ឋមន្ត្រីឡាវ និងក្នុងព្រឹកថ្ងៃដដែលនេះដែរ លោក នាយក ថង់លុន ស៊ីស៊ុលិត បានជួបពិភាក្សាអំពីវិធីការដោះស្រាយបញ្ហា ជាមួយនឹងនាយករដមន្ត្រី ហ៊ុន សែន ជាបន្ទាន់ និងបានព្រមព្រៀងគ្នា អោយ ភាគីទាំងពីរដក់កងកម្លាំងរបស់យោធារបស់ខ្លួនទាំងអស់ចេញពីតំបន់អូរអា ឡៃត្រឡប់ទៅអង្គភាពដើមវិញ; ប្រគោលឱ្យក្រសួង ការបរទេស ក៏ដូចជាគ ណៈកម្មាការព្រំដែននៃភាគីទាំងពីរ បន្តពិភាក្សានិងចរចាជាមួយគ្នា បន្តបង្កើត

កត្តាអំណួយអោយមានការពិភាក្សាជាទៀងទាត់នៅពេលដែលមានបញ្ហាមួយណាកើតឡើង។

ក្រោយពីសេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរនៅថ្ងៃទី 12 ខែ សីហា ឆ្នាំ 2017 ដោយសារតែសេចក្តីទុកចិត្តក្នុងមិត្តភាពនៃប្រទេសទាំងពីរក៏ដូចជាថ្នាក់ដឹកនាំនៃប្រទេសកម្ពុជា, ភាគីឡាវបានដក់កងកម្លាំងយោធាខ្លួនចេញពីអូរអាឡៃ។ ប៉ុន្តែ ផ្ទុយទៅវិញភាគីកម្ពុជាត្រឹមតែដកកងកម្លាំងគាំទ្រប្រឡប់ទៅវិញតែប៉ុន្នោះ ប៉ុន្តែកងកម្លាំងយោធាព្រំដែនដែលឈរជើងប្រចាំការនៅតំបន់នេះមិនទាល់ដក់ទៅវិញនៅឡើយទេ។ លើសពីនេះទៅទៀត ភាគីកម្ពុជាបានផ្លាស់ប្តូរកងកម្លាំងមកជំនួសទីតាំងដើមរបស់យោធាឡាវនិងដាក់ទង់ជាតិខ្លួន ដើម្បីប្រកាសអធិបតេយ្យភាពរបស់កម្ពុជានិងបានអបអរសាទរជ័យជម្នះលើតំបន់នេះ។ ថ្ងៃទី 18 ខែ សីហា ឆ្នាំ 2017, ឯកឧត្តម លោក ថង់លុន ស៊ីស៊ុលិត នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាពិបតេយ្យប្រជាមានិតឡាវ បានផ្ញើលិខិតមួយទៅកាន់លោកនាយករដ្ឋមន្ត្រីកម្ពុជា ដើម្បីបញ្ជាក់ពីជំហររបស់ភាគីឡាវអំពីការដោះស្រាយបញ្ហានេះ, ដែលមានខ្លឹមសារសំខាន់គឺ ៖ លោកនាយករដ្ឋមន្ត្រីឡាវបានសង្កត់ធ្ងន់ឡើងវិញនូវកិច្ចព្រមព្រៀងរបស់ភាគីទាំងពីរ ដែលបានឯកភាពជាមួយគ្នានៅថ្ងៃទី 12 ខែ សីហា ឆ្នាំ 2017 កន្លងមកនិងស្នើអោយនាយករដ្ឋមន្ត្រីកម្ពុជាសុខចិត្តអនុវត្តនៃកិច្ចព្រមព្រៀងយ៉ាងតឹងរឹងស្មោះត្រង់ ទាំងនេះដើម្បីរួមគ្នាការពារនិងថែរក្សារប្រពៃណីដ៏ល្អប្រសើអោយកាន់តែយូរអង្វែងដូចខ្លឹមសារគឺ៖ តំបន់នេះមិនទាល់ចុះត្រួពិនិត្យ និង កំណត់ខ្សាយព្រំដែនរួមគ្នាដោយសារភាគីទាំងពីរមានគំនឹតខុសគ្នាអំពីឯកសារនៃការគូសខ្សែព្រំដែន ទើបដំបន់នេះជាតំបន់នៅសេសសល់ដែលភាគីទាំងពីរបានឯកភាពគ្នាថាជាតំបន់នៅសេសសល់មត្តិភាព និង ហាមធ្វើកច្ចិការណាមួយ ត្រូវរក្សាតំបន់នេះមានស្ថានភាពដូចដើម

រហូតដល់ភាពគីទាំងពីរសម្រេចការចុះត្រួតពិនិត្យ និង បោះបង្គោលព្រំ ដែនជាស្ថាពរ។

ដើម្បីទប់ស្កាត់ព្រឹត្តិការណ៍នេះ មិនអោយកើនឡើងនិងបន្ធូរបន្ថយភាពតានតឹងលើបញ្ហានេះទេ, នៅថ្ងៃទី 01 ខែ កញ្ញា ឆ្នាំ 2017 នាយករដ្ឋមន្ត្រីនៃឡាវនិងនាយករដ្ឋមន្ត្រីនៃកម្ពុជា បានជួបពិភាក្សារជាមួយគ្នាជាសារថ្មីម្តងទៀតនៅរាជធានីភ្នំពេញ ហើយបានឯកភាពជាមួយគ្នាដូចខាងក្រោម ៖

- យល់ព្រមអោយរដ្ឋមន្ត្រីក្រសួង ការបរទេសឡាវនិងកម្ពុជា ជួបពិភាស្សារគ្នានៅពេលឆាប់ៗនេះ ដើម្បីពិភាក្សារជាមួយគ្នាយ៉ាងលម្អិតលម្អិលអំពីវិធីការដោះស្រាយបញ្ហា។

- ឯកភាពអោយគណៈកម្មាការចម្រុះព្រំដែនរបស់ភាគីទាំងពីរ ចុះត្រួតពិនិត្យនៅលើដីជាក់ស្តែង ជាមួយគ្នានៅចំណុច 04 តាមការស្នើរបស់ភាគីកម្ពុជាគឺ ទីទាំងបង្គោលលេខ 033, ទីទាំងផ្លូវថ្នល់លេខ 13/7 ប្រវែង 7,8 គីឡូម៉ែត្រ, តំបន់វើនខាមនិងតំបន់បង្គោលលេខ 032 - 032/6។

- អោយគណៈកម្មការចម្រុះព្រំដែន ចុះត្រួតពិនិត្យនៅលើដីជាក់ស្តែងនៅតំបន់កែងតម៉ រខោយ-អូរតង៉ាវ ដើម្បីកំណត់ទីតាំងបង្គោលព្រំដែននិងព្រមព្រៀងគ្នាបោះបង្គោលព្រំដែនអោយសម្រេចយ៉ាងឆាប់។ ចំណុចណាឯកភាពគ្នាត្រូវតែបោះបង្គោលភ្លាម ដើម្បីឆ្ពោះទៅរកការបោះបង្គោលជាបន្តបន្ទាប់អោយបានសម្រេច។

- នាយករដ្ឋមន្ត្រីប្រទេសទាំងពីរបានព្រមព្រៀងគ្នាសរសេរលិខិតជាផ្លូវការផ្ញើទៅកាន់លោកប្រធានាធិបតីប្រទេសបារាំង ដើម្បីសម្នើអោយរដ្ឋាភិបាលបារាំងជួយនិងផ្តល់ឯកសារផ្សេងផ្សេងដែលពាក់ពាន់ ដើម្បីប្រើប្រាស់ជាទន្ន័យនិងភស្តុតាងក្នុងការដោះស្រាយបញ្ហាព្រំដែនរវាងប្រទេសទាំងពីរ។

ទាំងអស់នេះគឺជាកិច្ចយល់ព្រមគ្នារវាងអ្នកដឹកនាំរដ្ឋាភិបាលឡាវនិងកម្ពុជាដែលបានផ្តល់ដំណឹងជាព័ត៌មានផ្សព្វផ្សាយអោយប្រជាជនប្រទេស

ទាំងពីរក៏ដូចជាអន្តរជាតិ បានជ្រួតជ្រាបដល់ការខិតខំព្យាយាមស្វែងរកដំណោះស្រាយដោយសន្តិវិធី។

